សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

# KhmerPost USA

Free Copies

Email:Khmerpostusa@gmail.com
www.khmerpostusa.com

Vol. 15. Issue 369, Jan 30, 2025 | Direct: 978-656-8141

Lowell - Lynn - Revere - MA * Providence - Cranston - RI

# ប្រធានាធិបតីថ្មី៖ "សម័យមាសចាប់ផ្ដើមពីថ្ងៃនេះទៅហើយ"

ដោយ ខ្មែរប៉ុស្ដិ៍ស.រ.អា

លោក ឌណាល ត្រម ជាប្រធានាធិបតីទី៤៧ នៃសហរដ្ឋអាមេរិកបានធ្វើពិធីស្បថចូលកាន់អំណាចនៅក្នុងសាលមួយនៃវិមានកាពីតូល នៅម៉ោង១២គត់ នៃថ្ងៃទី២០ ខែ មករា ឆ្នាំ២០២៥ ដែលខុសពីទម្លាប់រាល់ដងតែងតែធ្វើនៅខាងក្រៅបរិវេណ។

ពិធីផ្ទេរអំណាចពីប្រធានាធិបតី ចូ បាយឌិន ទៅប្រធានាធិបតីថ្មី ឌណាល ត្រម ធ្វើឡើងក្នុងបរិយាកាសយ៉ាងប្រុងប្រយ័ត្ន ដោយមានកម្លាំងការពារសន្តិសុខជាង២ម៉ឺននាក់ ។

គេសង្កេតឃើញមានលោកប្រធានាធិបតី ចូ បៃឌិន និងស្ត្រីទី១ អតីតប្រធានាធិបតីអាមេរិកាំង ៣រូប មកចូលរួម គឺលោក គ្លីន តុន និងភរិយា លោក ចច ប៊ូស និងភរិយា និងលោក បារ៉ាក់ អូបាម៉ា ប៉ុន្តែគេមិនបានឃើញអ្នកទាំងនោះនៅរហូតដល់ទីបញ្ចប់នៃពិធីស្បថរបស់ចូលកាន់អំណាចរបស់លោកប្រធានាធិបតីទី៤៧ នៃសហរដ្ឋអាមេរិកនោះទេ ។

សូមអានទំព័រទី០២



លោក ឌណាល ត្រម បានថ្លែងការពីនយោបាយថ្មី របស់លោក បន្ទាប់ពីចូលកាន់អំណាចបាន១០នាទី

## សោកនាថកម្មលើរូប លឹម គឹមយ៉ា នៅបាងកក

នៅឡូវែល ដោយ ពីន សំខុន

លោកអតីតសមាជិកសភាគណបក្សសង្គ្រោះជាតិឆ្នាំ២០១៣ លឹម គឹមយ៉ា បានត្រូវខ្មាន់កាំភ្លើងបាញ់សម្លាប់ នៅទីក្រុងបាងកកកាលពីថ្ងៃទី៧មករា២០២៥ វេលាម៉ោង៥រសៀល នៅពេលលោកធ្វើដំណើរចេញពីខេត្តសៀមរាប តាម

តទៅទំព័រទី០៧



អតីតតំណាងរាស្ត្រសង្គ្រោះជាតិ លឹម គឹមយ៉ា ឆ្នាំ២០១៣ ជាសមាជិកសភាដែលហ៊ាននិយាយមិនចេះខ្លាច

## កសិករទទូចឱ្យលោក ហ៊ុន ម៉ាណែត ដោះស្រាយបញ្ហាតម្លៃស្រូវចុះថោក

សូមអាននៅទំព័រទី០៨



## ពលរដ្ឋខ្មែរស្នើរាជរដ្ឋាភិបាលចាត់ការម៉ឺងម៉ាត់លើមន្ត្រីកម្លាំងប្រដាប់អាវុធពាក់ព័ន្ធគ្រឿងញៀន

សូមអាននៅទំព័រទី១៦



## ក្រុមតន្ត្រីអរុណរះនៅឡូវែល

ឡូ ថ្ងៃទី១៩មករា២០២៥ សុទ្ធតែអតីតក្រុមតន្ត្រីករជើងចាស់

សូមអាននៅទំព័រទី២០



## ព្រឹត្តិការគួរឲ្យចង់ដឹងក្នុងពិភពលោក

សូមអាននៅទំព័រទី០៤



# ការស្បត់ចូលកាន់អំណាចជាប្រធានាធិបតីសហរដ្ឋអាមេរិករបស់លោក ឌណាល់ ត្រាំ

វ៉ាស៊ីនតោន ថ្ងៃទី២០មករា២០២៥

អតីតប្រធានាធិបតីអាមេរីកាំង ៣រូប គឺលោក បារ៉ាក់ អូបាម៉ា លោក គ្លីង តុន នឹងលោក ជ័ច ប៊ូស រួមទាំងលោកស្រី គេសង្កេតឃើញថា មិនបានចូលរួមក្នុងពិធីស្បថរបស់លោកប្រធានាធិបតីថ្មីទី៤៧របស់សហរដ្ឋអាមេរិកនោះទេ នឹងមិនចូលរួមក្នុងពិធីស្បត់របស់លោក ឌណាល ត្រាំ ជាប្រធានាធិបតីទី៤៧របស់ ស.រ.អា ទេ។

លោក ឌណាល ត្រាំ បានធ្វើការស្បថចូលកាន់អំណាច ជាប្រធានាធិបតីនៃសហរដ្ឋអាមេរីក នៅក្នុងវិមានកាពីតូលកាលពីថ្ងៃទី២០មករា២០២៥បន្ទាប់ពីលោកស្រី កាម៉ាឡា ហារីស បានទទួលស្គាល់ថា«លោកស្រីបានចាញ់ឆ្នោតយ៉ាងពិតប្រាកដ»រួចមក ដែលករណីដូចគ្នានេះ មិនបានកើតឡើងទេ កាលលោក ត្រាំ ចាញ់ឆ្នោតលោក ជោ បាយដិន កាលពីឆ្នាំ២០២០, មិនតែប៉ុណ្ណោះ លោក ត្រាំ បានធ្វើអំពើមិនគប្បីនឹងខុសច្បាប់យ៉ាងច្រើន ចោទប្រកាន់ថាមានអ្នកលួចសន្លឹកឆ្នោតរបស់លោក លោកបានបង្ខំឲ្យមន្ត្រីក្នុងរដ្ឋខ្លះ កែរលទ្ធផលនៃការរាប់សន្លឹកឆ្នោត រហូតដល់ពន្យុះឲ្យមានកូដករ វាយសម្រុកចូលវិមានកាពីទូល អុកឡុកមិនឲ្យប្រកាសលទ្ធផលបោះឆ្នោត ទៀតផង។ តែនៅលើកនេះ លោក ជោ បាយដិន បានធានាសុវត្ថិភាពដល់បរិវេណកាពីតូល មិនឲ្យអំពើហឹង្សាណាមួយកើតឡើងបានម្តងទៀតឡើយ ។

តើលោក ឌណាល ត្រាំ ជានរណា? លោកត្រាំ ជាមហាសេដ្ឋី ជាអតីតប្រធានាធិបតីអាណត្តិទី១នាចន្លោះឆ្នាំ ១៩១៦ ដល់ ២០២០ តែលោកមិនបានជាប់ឆ្នោតនៅអាណត្តិទី២របស់លោកភ្លាមទេ ហេតុនេះហើយបានជាលោកអាចឈរឈ្មោះម្តងទៀត សម្រាប់ការបោះឆ្នោត នៅថ្ងៃទី៥វិច្ឆិកាមុននេះបាន ដែលនោះជាអាណត្តិទី២របស់លោក។លោកត្រាំពុំមែនជាអ្នកនយោបាយទេ តែជាអ្នកសេដ្ឋកិច្ច ដែលបានប្រកួតឈ្នះដំណែងនយោបាយជាន់ខ្ពស់បំផុតនៅសហរដ្ឋលោកប្រកាន់ចន្ទនយោបាយ«ស្តាំផុតនិយម»ដែលបានធ្វើឲ្យអ្នកបោះឆ្នោតស្បែកសភាគកណ្តាលអាមេរីក ពេញចិត្តនឹងចូលរួមដោយប្រជាពលរដ្ឋក្រីក្រជាទូទៅ មានជនជាតិអាស៊ី ជនស្បែកខ្មៅ ឬស្បាទីសក៏ចូលចិត្តឲ្យលោក ត្រាំ ក្នុងចំនួនច្រើនជាងពេលមុន ឲ្យមកដឹកនាំប្រទេសម្តងវិញដែរ, តែពុំបានប្រមូលប៉ុំអ្នកនយោបាយ ខាងគណបក្សសាធារណរដ្ឋបានទាំងមូលទេ, លោក



ប្រធានាធិបតីទី៤៧ នៃសហរដ្ឋអាមេរិក ឌណាល ត្រម ថតនៅមុខជញ្ជាំងព្រំដែលមិចស៊ិច

បានឃោសនាធ្វើការសន្យាជាច្រើន ដែលមានលក្ខណៈហួសហេតុ នៅក្នុងការគ្រប់គ្រងនៅក្នុងសេដ្ឋកិច្ច នៅក្នុងអន្តោប្រវេសន៍ ឬនៅក្នុងសង្គមកិច្ច ដែលម្ចាស់ឆ្នោតកំពុងតែច្រូលច្របល់ ដោយសង្ឃឹមថានឹងមានការផ្លាស់ប្តូរ តែពុំទាន់មានភាពច្បាស់លាស់នៅឡើយ។ មុនឡើងកាន់អំណាច៥ថ្ងៃ លោក ឌណាល ត្រាំ បានទទួលនូវការលុបលាងទោសឧក្រឹដ្ឋរបស់លោក ដោយអនុគ្រោះ នៅថ្ងៃទី១៥មករានេះ តែនៅមានករណីធ្ងន់ធ្ងរខ្លះទៀត តុលាការនៅពុំទាន់លើកសវនាការចេញមកនៅឡើយទេ ដោយទុកឲ្យលោកត្រាំ អាចបំពេញភារៈកិច្ចឲ្យបានពេញលេញ នៅ៤ឆ្នាំខាងមុខសិន។

តើលោក ឌណាល ត្រាំនឹងធ្វើអ្វីខ្លះនៅក្នុងសហរដ្ឋ? ដោយសារនៅពេលឃោសនា លោកត្រាំបានឲ្យគេដឹងថាលោកនឹងធ្វើការលើកលែងទោស ឲ្យជនដែលត្រូវគេចាប់កាលពីថ្ងៃ៦មករា២០២១ ពីការវាយលុកចូលនៅវិមានកាពីតូល, លោកនឹងធ្វើ«របងកាពារព្រំដែន»នៅខាងត្បូងជាប់ប្រទេស ជាប់ម៉ិកស៊ិក បញ្ចប់, លោកនឹងចាប់«បញ្ជូនជនអន្តោប្រវេសន៍» រាប់លាននាក់ដែលមករស់នៅខុសច្បាប់ ទៅកាន់ប្រទេសដើមរបស់ខ្លួនវិញ,លោកនឹងប្តូរផែនការ«ជំនួយសុខភាពអូបាម៉ាObamacare»ចោលចេញ, នឹងកែររបៀបបើកប្រាក់សម្រាប់អ្នកចូលនិវត្តន៍ ទៅតាមថ្ងៃកំណើត, តម្លៃទិញការ«ធានារ៉ាប់រងសុខភាព»នឹងត្រូវឡើងថ្លៃ, ឥវ៉ាន់ចាំបាច់មួយចំនួន ដែលនាំចូលនឹងឡើងថ្លៃដូចគ្នា ដោយអត្រាពន្ធនាំចូលនឹងកើនចំនួន,ក្រសួងមួយចំនួននឹងត្រូវលប់ចោល រីឯមន្ត្រីជាច្រើននឹងត្រូវបណ្តេញពីកាងារ ដោយលោកយល់ថាជាមន្ទីរឥតប្រយោជន៍, លោកនឹងធ្វើច្បាប់មិនឲ្យកូនជនបរទេស ដែលកើតនៅលើទឹកឌីសហរដ្ឋ មានសញ្ជាតិអាមេរីកាំងជាស្វ័យប្រវត្តិ ,...។

ក្នុងអាណត្តិរបស់លោក នឹងមានប្រតិកម្មខ្លះក្នុងការធ្វើច្បាប់ សម្រាប់អនុវត្តន៍នយោបាយថ្មីរបស់លោក ត្រាំ ដោយនៅឯសភា គណបក្សសាធារណរដ្ឋ បានឈ្នះឆ្នោតលើគណបក្សប្រជាធិបតេយ្យ ក្នុងចំនួនតិចពេក ដែលអាចនឹងធ្វើឲ្យការអនុវត្តន៍ច្បាប់មានការយឺតយ៉ាវឬក៏ត្រូវប្រើពេលសម្រាប់ចរចាគ្នា, នៅមានចៅហ្វាយរដ្ឋខ្លះ ដែលកាន់កាប់ដោយគណបក្សប្រជាធិបតេយ្យ បានសន្យាថានឹង«មិនអនុវត្តន៍ទេ នូវបទបញ្ជាលោក ត្រាំ» ណាដែលហួសហេតុហើយនៅក្នុងដែននៃអធិបតេយ្យភាពរបស់ពួកគេ, លោកស្រី កាម៉ាឡា ហារីស ដែលបានក្លាយជាមេក្រុមនៃបក្សប្រឆាំង បានប្រកាសថា នឹងបន្តរការតស៊ូរបស់ខ្លួនប្រឆាំងនឹង ត្រាំ គឺមិនទាន់ចប់ជាមួយនឹងការបោះឆ្នោតនោះ នៅឡើយទេ,...ក្រុមកសិករបានប្តឹមតវ៉ាឲ្យរក្សាជនអន្តោប្រវេសន៍ខ្លះ ដើម្បីឲ្យមានកម្មករធ្វើការក្នុងស្រែចំការ... ។

តើទំនាក់ទំនងកិច្ចការបរទេសអាមេរីកនឹងទៅជាយ៉ាងណា? ដោយសារតែមានបទពិសោធន៍ពីអាណត្តិមុន នឹងភាពមិនប្តូរផ្លាស់ ដែលគេដឹង នាឱកាសឃោសនាបោះឆ្នោត គេអាចទាយទុកបានថា«នឹងមានការប្រែប្រួលគួរឲ្យបារម្មណ៍»ដូចជា៖

១ សង្គ្រាមនៅអ៊ុយក្រែនអាចនឹងត្រូវបញ្ចប់ បើ ឌណាល ត្រាំ សម្រេចចិត្តកាត់ជំនួយយោធាទៅឲ្យអ៊ុយក្រែន បានន័យថាអ៊ុយក្រែននឹងគ្មានមធ្យោបាយបន្តរសង្គ្រាមជាមួយរុស្ស៊ី ទៅមុខបានទេ។ តែនៅពេលនេះ ណាតូ កំពុងតែត្រៀមខ្លួនចាប់យកអ៊ុយក្រែន ជំនួសសហរដ្ឋអាមេរីក នៅពេលប្រទេសនេះដកខ្លួនចេញពីការជួយអ៊ុយក្រែន។

២ ប្រទេសចិនកុម្មុយនីស្ត អាចនឹងងើបឡើង គម្រាមតំបន់សមុទ្រចិនខាងត្បូង ជាបន្តរទៅទៀត មានតាយវ៉ាន់ មានហ្វីលីពីន ឬវៀតណាម...ជាដើម ដូចកាលពីមុនម្តងហើយ, លោក ឌណាល ត្រាំ ធ្លាប់ទាមទារតាយវ៉ាន់ កាលពីខែមុននេះថា«តាយវ៉ាន់ត្រូវតែចំណាយបក្រាក់ ដើម្បីឲ្យអាមេរីកមកកាពារតាយវ៉ាន់»...។

៣ អាមេរីកអាចនឹងដកខ្លួនពីកម្រោងកាពារបរិហាន កាពារការឡើងកំដៅនៅពិភពលោក ជាមួយអ.ស.ប. ហើយមិនត្រឹមតែប៉ុណ្ណោះ នយោបាយលោក ត្រាំ នៅឆ្នាំក្រោយ គឺនៅតែបន្តរផលិតរថយន្តដែលប្រើឋាមពលប្រេងក្រោមដីតែដដែល ចំពេលដែលពិភពលោក បានប្តើមបញ្ឈប់ការប្រើឋាមពលប្រភេទនេះ ដែលនឹងកាត់បន្ថយផ្សែងពុល ខ្លះៗអស់ទៅហើយ។

៤ លោក ត្រាំ នឹងតម្លើងពន្ធនាំចូលចំនួន៦០% សម្រាប់ទំនិញនាំចូលពិចិន ២៥% ទំនិញនាំចូលពី កាណាដា ពីម៉ិកស៊ីក ហើយនឹងតម្លើងពន្ធ១០០% ដល់ប្រទេស«ប្រ៊ីក BRICKS»ណាដែលចង់ប្តូររូបីយប័ណ្ណដុល្លាអន្តជាតិ។

ទាំងនោះមិនទាក់ទងនឹងបញ្ហាមនោគមន៍វិជ្ជារបស់សហរដ្ឋអាមេរីកនោះទេ តែកំរឹតនៅត្រឹមតែផលប្រយោជន៍

តទៅទំព័រទី១១

# Massachusetts Ranks #1 in National Education Assessment

BOSTON – Today, the U.S. Department of Education announced that Massachusetts students ranked number one among states on the National Assessment of Educational Progress (NAEP) — often called the Nation's Report Card — last year. Massachusetts students received the highest numeric score of any state on all four assessments – fourth and eighth grade math and reading – and continues to rank first in the nation overall. Scores across the country, including Massachusetts, continue to lag pre-pandemic levels, and the Healey-Driscoll Administration has put in place nation-leading early literacy and tutoring programs to address those gaps.

The NAEP is the only nationally representative and continuing assessment of America's students' knowledge in subjects such as math, reading, science and writing. The assessment tests representative samples of fourth- and eighth-grade students in all 50 states, Washington, D.C., Puerto Rico and the Department of Defense Education Activity. The tests are generally administered every two years.

"Massachusetts is #1 in education because of our incredible students, families, educators and school officials," said Governor Maura Healey. "These are more than just test scores – they represent our commitment to making sure that every student graduates our schools with the skills they need to succeed in the future. We know there is much work left to do build back from the pandemic and support every child. Our administration is going to keep investing in our schools, promoting early literacy and tutoring, reducing chronic absenteeism, and helping our students and educators every step of the way."



Photo via NAEP

"These nation-leading results are the product of hard work and investment, and we will continue to focus on early literacy and other foundational skills that set students up for success," said Lieutenant Governor Kim Driscoll. "Congratulations to all of the students and educators who hustled to make sure they had the knowledge and skills to perform well on these tests and in the future."

The ability for students to read and read well has been a priority for the Healey-Driscoll Administration, which created the nation-leading, multi-year strategy Literacy Launch: Reading Success from Age 3 through Grade 3. Literacy Launch makes sure schools, educators and students have access to high-quality, evidence-based reading instruction through literacy materials, technical support, coaching and professional development for educators. The administration secured $20 million for the first year, with the first grants going out to schools earlier this week. Governor Healey's FY26 budget includes $25 million for the second year of Literacy Launch and $25 million for a literacy high dosage tutoring initiative to address pandemic learning loss and accelerate literacy growth for students.

Please see /22

AccuCare
Home Care Agency
ភ្នាក់ងារថែទាំអ្នកជំងឺតាមផ្ទះ
Group Adults Foster Care Program
កម្មវិធីថែទាំមនុស្សពេញវ័យ
144 Merrimack Street • Suite 404
Lowell, MA 01852 • 617-783-7177



Open for enrollment.
Persons with disability and chronic illnesses at no cost to patients.
We provide an individual care plan developed by a registered nurse and case manager.
Service plan includes medication management, personal care service at home, a Nurse and Case Manager monitoring ongoing needs.
Patient must have Masshealth Standard to qualify.
We accept United, Senior Whole Health, Fallon and Commonwealth Care Alliance.

បើកទទួលចុះឈ្មោះ
ជនមានពិការភាព និងអ្នកជំងឺរ៉ាំរ៉ៃ ដោយឥតគិតថ្លៃ។
យើងផ្តល់ផែនការថែទាំអ្នកជំងឺជាបុគ្គលដោយគិលានុបដ្ឋាយិកាដែលមានចុះបញ្ជីត្រឹមត្រូវ និងគ្រូពេទ្យគ្រប់គ្រងអ្នកជំងឺ។
ផែនការសេវាកម្មរួមមាន ការគ្រប់គ្រងឱសថ សេវាថែទាំដោយផ្ទាល់តាមផ្ទះ គិលានុបដ្ឋាយិកា
និងគ្រូពេទ្យគ្រប់គ្រងអ្នកជំងឺពិនិត្យតាមដានជាប្រចាំតាមតម្រូវការ។
ដើម្បីមានលក្ខណៈគ្រប់គ្រាន់ អ្នកជំងឺត្រូវតែមាន Masshealth Standard ។
យើងទទួល United, Senior Whole Health, Fallon
និង Commonwealth Care Alliance ។

# ព្រឹត្តិការគួរឲ្យចង់ដឹងក្នុងពិភពលោក

Mass. ថ្ងៃទី១៧មករា២០២៥

**១.សង្គ្រាមនៅអ៊ុយក្រែន:** សង្គ្រាមនេះទំនងជានឹងត្រូវចប់ឆាប់ៗនេះហើយ ដោយលោក



លោកវ្លាឌីមៀ ពូទីន ប្រធានាធិបតីរុស្ស៊ី

ឧណាលត្រាំប្រធានាធិបតីជាប់ឆ្នោតបានប្រកាសថា«លោកនឹងបញ្ចប់សង្គ្រាមនេះនៅថ្ងៃទី១ ដែលលោកឡើងកាន់ដំណែង» នៅថ្ងៃទី២០មករា។រីឯលោកវ្លាឌីមៀពូទីនប្រធានាធិបតីរុស្ស៊ីក៏និយាយថា«ចង់បញ្ចប់សង្គ្រាមនេះឲ្យបានឆាប់»ប៉ុន្តែនៅតែសង្វើញវាយលុកនៅតំបន់ខាងកើតអ៊ុយក្រែនដដែល ។

ចំណែកលោក វីឡូឌីមៀ ដេឡិនស្គី ប្រធានាធិបតីអ៊ុយក្រែន ក៏បាននិយាយថា«ចង់ឲ្យបញ្ចប់សង្គ្រាម បើទោះជាត្រូវខាតបង់ទឹកដីខ្លះក៏ដោយ» ក៏ប៉ុន្តែនៅតែទប់ទល់



បំពង់ឧស្ម័នចេញពីរុស្ស៊ីកាត់តាមអ៊ុយក្រែន និងកាត់អឺរ៉ុប ត្រូវបានបិទដោយ ហ្សេលែនស្គី

យ៉ាងស្វិតស្វាញសម្លាប់ទ័ពកូរ៉េខាងជើង សម្ព័ន្ធមិត្ររុស្ស៊ីឈ្លានពាន បាន ជាង៣០០០នាក់ហើយ។ ថ្មីៗនេះទៀត ដេឡិនស្គី បានបញ្ជាឲ្យកាត់ផ្តាច់បំពង់បង្ហូរឧស្ម័ន ដែលឆ្លងកាត់អ៊ុយក្រែនទៅប្រទេសអឺរ៉ុប(ដូចជាប្រទេសស្លូវ៉ាគី) គឺជាប្រាក់ចំណូលដ៏សន្ធឹកសន្ធាប់ ដែល ដេឡិនស្គីនិយាយថា«គឺជាបំពង់សម្រាប់បង្ហូរឈាមពលរដ្ឋអ៊ុយក្រែន» នេះគឺជាយុទ្ធសាស្ត្រដ៏ប្រសិទ្ធភាព ដើម្បីកាត់សសៃឈាម តបទៅរុស្ស៊ីវិញ។ ប្រទេសអឺរ៉ុបដែលខ្វះឧស្ម័នទាំងនោះ អាចនឹងសងសឹកទៅអ៊ុយក្រែនវិញនៅពេលក្រោយ។

អ៊ុយក្រែននៅតែវាយប្រហារគ្នាជាង២ឆ្នាំមកហើយ នាតំបន់ដុងបាស នាខាងកើតរហូតដល់ភាគខាងត្បូងនៃអ៊ុយក្រែន ដោយសារអ៊ុយក្រែនមានអាវុធយុទ្ធភ័ណ្ឌគ្រប់គ្រាន់ពីអាមេរិកលោកបាយដិន នឹងពីសម្ព័ន្ធមិត្រអូតង់(ទ័ពសហភាពអឺរ៉ុប)ពិសេសទៅទៀតនោះយុទ្ធជនអ៊ុយក្រែនមានទឹកចិត្តប្រយុទ្ធការពារជាតិខ្លាំងខ្លាបំផុត... តែសហរដ្ឋអាមេរិកនៃរដ្ឋបាលលោក ឧណាលទ្រាំ ទំនងជានឹងកាត់ផ្តាច់ជំនួយគ្រប់យ៉ាងទៅឲ្យអ៊ុយក្រែង នៅបន្ទាប់ពីថ្ងៃឡើងកាន់ដំណែង ដែលនឹងមិនឲ្យប្រទេសអ៊ុយក្រែននេះបន្តសង្គ្រាមបានទេ...រុស្ស៊ីរបស់លោក ពូទីន អាចនឹងឈ្នះដោយស្វ័យប្រវត្តិបាន ... យើងចាំមើលនឹងរាយការជាបន្តទៅទៀត នាពេលក្រោយ ៕

**២ សង្គ្រាមនៅគ្គាស្គា: មានកិច្ចព្រមព្រាងឈប់បាញ់គ្នាថ្មីមួយទៀត**

អ៊ីស្រាអែលនឹងហាម៉ាស់ បានចុះហត្ថលេខាព្រមព្រាង«ឈប់បាញ់គ្នានៅគ្គាស្គា» កាលពីថ្ងៃសៅរ៍ទី១៨មករា កន្លងទៅ ដោយមានការសម្របសម្រួលដោយប្រទេសកាកតា អេជីប នឹងសហរដ្ឋអាមេរិក។ ដំណឹងនេះបានធ្លាក់ចំពេលសភាអាមេរិកកំពុងធ្វើកិច្ចប្រជុំពេញអង្គ ធ្វើឲ្យសមាជិកទាំង២បក្សទទួលអបអរសាទរស្របគ្នាបន្ទាប់ពីសង្គ្រាមរ៉ាំរ៉ៃចំនួន១៥ខែមក បានសម្លាប់មនុស្សជាង៦ម៉ឺននាក់ របួសប្រមាណ១០ម៉ឺននាក់ដែលភាគច្រើនសុទ្ធសឹងជាជនជាតិប៉ាឡេស្ទីនម្ចាស់ស្រុក នឹងខូចខាតផ្ទះសម្បែង នឹងហេដ្ឋារចនាសម្ព័ន្ធ ខ្ទេចខ្ទាំអស់រលីង។

កិច្ចព្រមព្រាងនេះចូលជាធរមាននៅថ្ងៃអាទិត្យទី១៩មករា ដោយតម្រូវឲ្យក្រុមហាម៉ាសដោះលែងចំណាប់ខ្មាំងជាតិអ៊ីស្រាអែល33នាក់ដំបូង ដែលខ្លួនបានចាប់យកទៅ(នៅសល់ជិត១០០នាក់ទៀតដែលមានជីវិតនៅឡើយ) ជាវគ្គៗតូច រហូតដល់អស់ ទល់នឹងការដោះលែងឈ្លើយប៉ាឡេស្ទិនរាប់ពាន់នាក់ដែលអ៊ីស្រាអែលចាប់បាន។ លោក ណេតាញ៉ាហ៊ូ នាយករដ្ឋមន្ត្រីអ៊ីស្រាអែលបានព្រមាណថា«អាចនឹងបន្តវាយប្រហារឡើងវិញ បើហាម៉ាស់មិនគោរពសន្យាខ្លួនទេនោះ»។ អ្នកសង្កេតការនិយាយថា«កិច្ចព្រមព្រាងឈប់បាញ់គ្នាលើកនេះ នៅផុយស្រួយណាស់»។

ក្នុងរយៈពេលសង្គ្រាម១៥ខែមកនេះ អ៊ីស្រាអែលមានលទ្ធភាពគ្រប់គ្រាន់ នឹងវាយចូលប្រទេសលីបង់ វាយចូលប្រទេសអ៊ីរ៉ង់ នឹងប្រទេសស៊ីរី (ដែលបានរលំកាលពីចុងខែធ្នូ២០២៤ហើយ)ដើម្បីទប់ទល់កងកម្លាំងដែលជាភេរវករអ៊ីស្លាមដែលបានពួតដៃគ្នា ចង់មកវាយរំលាយអ៊ីស្រាអែល ។

**៣ វិបត្តិនៅប្រទេសកាណាដា:**

នាយករដ្ឋមន្ត្រី យូស្ទីន ទ្រូដូ បានប្រកាសថានឹងលាលែងពីដំណែង កាលពីថ្ងៃទី៦មករា២០២៥ បន្ទាប់ពីបានជួបប្រធានាធិបតីជាប់ឆ្នោត ឧណាល ត្រាំ តវ៉ាពីការតម្លើងពន្ធ២៥% លើទំនិញនាំចូលពីកាណាដាទីអាមេរិក នៅពេលណាលោក ត្រាំ ចូលកាន់ដំណែងភ្លាម ។ លោក ទ្រូដូ ធ្វើសេចក្តីប្រកាសនេះ នៅពេលដែលលោកបាត់បង់ការគាំទ្រពីគណបក្សសេរីភាព(Liberal Party) របស់លោក ពីព្រោះលោកធ្លាប់ជាមិត្រជិតស្និតរបស់លោក ត្រាំ បែរជាធ្វើឲ្យមានការខូចខាតដល់ប្រយោជន៍កាណាដា។

លោក ត្រាំ ធ្លាប់បាននិយាយថា«នឹងតម្លើងអត្រាទំនិញ២៥% នាំចូលពីកាណាដានឹងម៉ិកស៊ិក នៅពេលដែលលោកចូលកាន់ដំណែង លើកលែងតែប្រទេសទាំង២ ឈប់ធ្វើឲ្យមានអាភៀននឹងជនអន្តោប្រវេសន៍ចូលមកអាមេរិកបាន»

នៅពេលនេះលោកទ្រូដូកំពុងតែពិគ្រោះជាមួយថ្នាក់ដឹកនាំតំបន់របស់កាណាដា ដើម្បីទប់ទល់នឹងវិបត្តដែលនឹងមកដល់បន្ទាប់ពីការគម្រាមមុនថ្ងៃ២០មករានៅឡើយ ហើយលោកថា«យើងបានត្រៀមទប់ទល់នឹងការសងសឹករបស់អា

តទៅទំព័រទី២១




# គេហដ្ឋានដែលសន្សំសំចៃថាមពល ជិតល្មមនឹងសម្រេចបាន។

ធ្វើឱ្យប្រសើរឡើងនូវផាសុកភាព និងប្រសិទ្ធភាពនៃគេហដ្ឋានរបស់អ្នកជាមួយនឹងការវាយតម្លៃថាមពលក្នុងផ្ទះដោយមិនគិតថ្លៃ។ វាគ្រាន់តែជាវិធីមួយក្នុងចំណោមវិធីជាច្រើនដែលយើងនៅទីនេះ ដើម្បីវាយតម្លៃផ្ទះរបស់អ្នក។

**នេះជារបៀបដំណើរការ៖**

- អ្នកឯកទេសថាមពលនឹងស្វែងរកកន្លែងដែលគេហដ្ឋានរបស់អ្នកអាចនឹងបាត់បង់ថាមពល ជាពិសេសក្នុងអំឡុងពេលខែក្តៅ និងត្រជាក់ខ្លាំង។
- អ្នកឯកទេសអាចដំឡើងឧបករណ៍សន្សំសំចៃថាមពលដោយមិនគិតថ្លៃ និងផ្តល់នូវការកែលម្អប្រព័ន្ធសន្សំសំចៃថាមពលក្នុងផ្ទះ ដូចជាការបញ្ចុះតម្លៃ 75-100% លើការដំឡើងអ៊ីសូឡង់ និងការបិទភ្ជិតខ្យល់ចេញដោយមិនគិតថ្លៃ។
- ពួកគេថែមទាំងអាចពិភាក្សាអំពីការបញ្ចុះតម្លៃ និងការលើកទឹកចិត្តចំពោះឧបករណ៍ដែលមានប្រសិទ្ធភាពថាមពល។

**99% នៃអតិថិជនដែលបានបញ្ចប់ការវាយតម្លៃថាមពលក្នុងផ្ទះនឹងណែនាំវាទៅមិត្តភក្តិ ឬសមាជិកគ្រួសារ។**

nationalgrid

**មោទនភាពជាអ្នកឧបត្ថម្ភរបស់**

mass save

**កំណត់ពេលវាយតម្លៃថាមពលក្នុងផ្ទះរបស់អ្នកនៅថ្ងៃនេះ។ ចូលទៅកាន់គេហទំព័រ**
**ngrid.com/assessment**
ឬទូរសព្ទទៅលេខ
**1-866-527-SAVE (7283)**

# អ្នកឧកញ៉ា សុខ គង់ ប្រកាសចែកអាំងប៉ាវ ធ្វើឲ្យមនុស្សស្លាប់៤នាក់ និងរងរបួស៥នាក់, ម្នាក់ទទួលបានលុយ៤ម៉ឺនរៀល និងអង្ករ២គីឡូក្រាម



សកម្មភាពប្រជាពលរដ្ឋប្រជ្រៀតគ្នានៅមុខផ្ទះអ្នកឧកញ៉ា សុខ គង់ យកអាំងប៉ាវ





ប្រជាពលរដ្ឋស្លាប់ និងអ្នករងរបួស



ឡានពេទ្យជួយសង្គ្រោះអ្នករងរបួសយកទៅពេទ្យ

(ភ្នំពេញ)៖ សេចក្តីរាយការណ៍បន្ថែម ពីភ្នាក់ងារ Fresh News បានឲ្យដឹងថា ករណីប្រជាពលរដ្ឋប្រជ្រៀតគ្នានៅមុខ ភូមិគ្រឹះអ្នកឧកញ៉ា សុខ គង់ ដើម្បីចាំយកអាំងប៉ាវ (លុយ៤ម៉ឺនរៀល និងអង្ករ២គីឡូក្រាម) ហើយខ្យល់គ នៅព្រឹកថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៥ បានស្លាប់កើនដល់៤នាក់ និងសង្គ្រោះ៥នាក់ផ្សេងទៀតនៅមន្ទីរពេទ្យ។

បើតាមសេចក្តីរាយការណ៍,ក្នុងចំណោមអ្នកខ្យល់គហើយបញ្ជូនទៅសង្គ្រោះនោះ នៅមន្ទីរពេទ្យកាល់ម៉ែតហើយស្លាប់២នាក់ និងនៅមន្ទីរពេទ្យអង្គឌួងស្លាប់២នាក់។

ថ្លែងប្រាប់បណ្តាញព័ត៌មាន Fresh News លោកឧត្តមសេនីយ៍ឯក ជួន ណារិន្ទ អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ បានបញ្ជាក់ថា ជនរងគ្រោះ៤នាក់បានស្លាប់ (ប្រុស២នាក់ និងស្រី២នាក់) ហើយជនរងគ្រោះទាំង៤នាក់ មានអាយុច្រើន ហើយប្រហែលជាខ្សោយខ្លាំងទើបបណ្តាលឲ្យស្លាប់ពេលប្រជ្រៀតគ្នានៅទីនោះ។

សូមជម្រាបថា ភូមិគ្រឹះអ្នកឧកញ៉ា សុខ គង់ ដែលប្រជាពលរដ្ឋនាំគ្នាទៅប្រជ្រៀតប្រមូលផ្តុំនោះ មានទីតាំងស្ថិតនៅតាមបណ្តោយមហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ។

ក្រោយមានហេតុការណ៍នេះកើតឡើង គេឃើញមានវត្តមានរបស់លោក ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ និងលោក សុខ ពេញវុធ អភិបាលរងរាជធានីភ្នំពេញ បានដឹកនាំកម្លាំងសមត្ថកិច្ច និងរថយន្តសង្គ្រោះបន្ទាន់ ដើម្បីជួយអន្តរាគមន៍ដឹកប្រជាពលរដ្ឋទៅសង្គ្រោះ និងសម្រួលចរាចរណ៍បំបែកនូវការជួបជុំនោះ៕

លោក ចាប ឌីណា អភិបាលរងខណ្ឌដូនពេញបានបញ្ជាក់ថាអត្តសញ្ញាណជនរងគ្រោះ រួមមាន៖

* សង្គ្រោះនៅពេទ្យអង្គឌួង ចំនួន ៤នាក់ ស្លាប់ចំនួន ០២នាក់ (ស្រី០១នាក់ ប្រុស០១នាក់)៖

- អ្នកស្លាប់ រួមមាន៖

១. ឈ្មោះ ម៉ាន់ ស៊ីយ៉ាន ភេទប្រុស អាយុ៧១ឆ្នាំ ភូមិដើមចាន់ សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ

២. ឈ្មោះ គង់ វ៉ាន់ថា ភេទស្រី អាយុ៦៧ឆ្នាំ ភូមិដំរៀងរាជ្យ ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង។

- អ្នកសង្គ្រោះបន្ទាន់៖

១. ឈ្មោះ ជិន តុន ភេទប្រុស អាយុ៧៥ ឆ្នាំ ភូមិអណ្តូង សង្កាត់គោករការ ខណ្ឌព្រែកព្នៅ

២. ឈ្មោះ ភេទប្រុស អាយុ (មិនទាន់ស្គាល់អត្តសញ្ញាណ)។

* សង្គ្រោះនៅពេទ្យកាល់ម៉ែត្រ ចំនួន៥នាក់

- សង្គ្រោះបន្ទាន់ (៣នាក់)៖

១. ឈ្មោះ កែវ ភឿន អាយុ៦៥ ឆ្នាំ ភេទ ប្រុស

២. ឈ្មោះ ហេង សានី ភេទប្រុស អាយុ ១៣ឆ្នាំ

៣. ឈ្មោះ នូ ស៊ី ភេទស្រី អាយុ ៣៥ឆ្នាំ

ករណីនេះគាត់ទៅមើលគេ ហើយលឺថាបងខ្លួនស្លាប់ក៏សន្លប់តែម្តង។

-ករណីស្លាប់ចំនួន២នាក់(ស្រី០១នាក់ ប្រុស០១នាក់)៖

១. ឈ្មោះ រឿន ចេក ភេទស្រី អាយុប្រហែល ៣៧ ឆ្នាំ ស្រុកកំណើត ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

២. ឈ្មោះ យស់ សារឿន ភេទប្រុស អាយុ៤៥ឆ្នាំ ស្រុកកំណើតភូមិកន្សោមអក ស្រុកកំពង់កំត្របែក ខេត្តព្រៃវែង៕

តមកពីទំព័រទី ០១

# សោកនាថកម្មលើរូប លឹម គឹមយ៉ា

រថយន្តឈ្នួល មកដល់ទីក្រុងបាងកក នៃប្រទេសថៃ ជាមួយភរិយាជាតិបារាំង នឹងឪពុកមារបស់លោក។ ខ្មាន់កាំភ្លើង




ប៉ូលិសបានចាប់ឃាតកដែលបានបាញ់សម្លាប់លោក លឹម គឹមយ៉ា

នោះ ជាជនជាតិថៃ បានត្រូវអាជ្ញាធរថៃ ចាប់ខ្លួនបាន នៅថ្ងៃបន្ទាប់ នៅពេល រត់គេចខ្លួនចូលមកដីខ្មែរ នឹងមាន ជនសង្ស័យម្នាក់ទៀត ជាជនជាតិខ្មែរ ដែលទំនងជាគេមានភស្តុតាងថា ជាអ្នក ចង្អុលបង្ហាញ ពីភិនភាគជនដែលត្រូវ រងគ្រោះ ដោយគ្រាប់កាំភ្លើងជនជាតិថៃ នោះ, ខ្មែរម្នាក់នោះឈ្មោះ ពេជ គឹមស្រ៊ុន លាក់ខ្លួនជិះរថយន្តឈ្នួលជាមួយ លឹម គឹមយ៉ា ដែរ ហើយក៏ត្រឡប់មកកម្ពុជា វិញ ដោយយន្តហោះ នៅល្ងាចដដែល នោះ។ គេដឹងថា ជនជាតិថៃដែដល់ គឺជា អតីតទាហ៊ានជើងទឹក ធ្លាប់ទទួលការ វេរលុយចូលគណនីយរបស់ខ្លួន ដោយ ជនជាតិខ្មែរម្នាក់ទៀត ដែលមានឈ្មោះ ថា លីរតនៈ រស្មី នៅខេត្តបាត់ដំបង ។

សកម្មភាពស៊ើបអង្កេតរបស់ប៉ូលិស ថៃ នៅតែបន្តរ ដូចគ្នានឹងសារពត៌មាន ថៃដែរ ដោយសារតែនេះជាករណីឃាដ កម្មឆ្លងប្រទេសដ៏ធំជាលើកទីមួយ តែ ភាពសហការរបស់រដ្ឋបាលខ្មែរ នៅ មិនទាន់មានជារហ័សរហួនសមរម នៅឡើយទេ ដោយមិនព្រមប្រគល់ខ្លួន ពេជ គឹមស្រ៊ុន តាមដីការចាប់ខ្លួន ដោយ បុរសនេះមានទំនាក់ទំនងជិតស្និទ ជាមួយ មន្ត្រីជាន់ខ្ពស់នៃរដ្ឋបាលកម្ពុជាផង។ ថ្វីត្បិតតែអ្នកនាំពាក្យរបស់រដ្ឋាភិបាល ភ្នំពេញ ប្រកែកមិនព្រមទទួលថា ឃាដ កម្មចំពោះ លឹម គឹមយ៉ា នេះមានទាក់ទង នឹងអ្នកនយោបាយនៅកម្ពុជាក៏ដោយ ក៏មតិសាធារណៈនៅតែចោទក្រកាន់ថា មានបញ្ជាឲ្យសម្លាប់ លឹម គឹមយ៉ា នោះ មកពីភ្នំពេញជាប្រាកដ។

**តើលោក លឹម គឹមយ៉ា ជានរណា?**

នៅពេលលោកស្លាប់ទៅ លោកមាន អាយុ៧៣ឆ្នាំ លោកបានរៀនចប់ មហាវិទ្យាល័យវិទ្យាសាស្រ្ត ខាងផ្នែក គណិតវិជ្ជា នៅឆ្នាំ១៩៧២ ហើយចេញ មកបន្តរការសិក្សា នៅទីក្រុងប៉ារីស, នៅ ទីនោះ លោកបានចេញទៅធ្វើការនៅ ក្រសួងហិរញ្ញវត្ថុបារាំង រហូតដល់ ចូលនិវត្តន៍ រៀបការជាមួយភរិយាបារាំង




ពេជ្រ គឹមស្រ៊ុន អ្នកអោយការទៅខ្មាំងកាំភ្លើងក្នុងការបាញ់សម្លាប់លោក លឹម គឹមយ៉ា

របស់លោក មានកូន៣នាក់។ លោក ធ្លាប់ជាយុវជន ស្មោះត្រង់នឹងប្រជាជាតិ តែងតែឈឺឆ្អាល់ចំពោះវាស្នាជាតិខ្មែរ មិនព្រមឆ្អែតឆ្អន់។ នៅពេលមកដល់ ស្រុកបារាំងភ្លាម លោកបានចូលរួម ជាមួយចលនាសេរី ដឹកនាំដោយព្រឹទ្ធាចារ្យខ្មែរ៧រូប មានលោក ស៊ិម វ៉ា (អតីត នាយករដ្ឋមន្ត្រី) លោក សុខ ឆុង (អតីត រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ) ... ដែល ធ្វើសកម្មភាពជួយរំដោះជាតិខ្មែរ ចេញពី របបនឹងនឹមកុម្មុយនីស្តក្រហម នាអម្លុង ឆ្នាំ១៩៧៥។ ពេលនោះ លោក លឹម គឹមយ៉ា បានបង្កើតកាសែត«មូលខ្មែរ»ជា ស្ថាបនិក ជាមួយលោក ស៊ិម វ៉ា ដែល តែងតែបញ្ចេញបតិមិនសំចៃមាត់ដូចគ្នា

តទៅទំព័រទី០៩

# Thai police investigates that the murder case of Lim Kimya is systematically prepared by the head of Cambodia

by RFA

Thai police investigative team has



លី រតនរស្មី ដែលបានផ្តល់លុយទៅអោយឃាតក ដើម្បីបាញ់សម្លាប់លោក លឹម គឹមយ៉ា

shown continuous video and evidence in the case of gunman who killed former National Rescue Party representative, Lim Kimya in Bangkok, Thailand, which is systematic. In that, the Thai court has issued a warrant for arresting a Khmer male suspect, known as Mr. «Diamond», involved in the conspiracy by telling the target to shoot the gunman to kill Mr. Lim Kimya.

Thailand's investigative team found that the cross-border murder was planned and executed in a system involving Thai and Cambodian suspects.

Commissioner of Police of Bangkok (Bangkok) Mr. Siam Bunsom (Siam Bunsom) holds a press conference on 9 January that the criminal court of Thailand has arrested another suspect involved in the killing of former National Salvation Party representative Lim Kimya since night. January 8th is coming. He stated that preliminary research by Thai police showed that the murder involved hiring gunmen to shoot the victim because usually the gunmen do not know the victim's face.

The suspect that the Thai court ordered to arrest is Mr. Pich Kimsrin, who is known as the vice chairman of the Central Market Commission and the grandson of the Governor of Phnom Penh, Mr. Khoung Sreng, accused of "conspiracy to kill people with intention".

The allegation comes after Thai police investigations officers collected video from Sovath cameras showing Mr. Pich Kimsrin's activities in connection with Thai gunman. In the video from the security camera, Mr. Pich Kimsrin followed Mr. Lim Kimya from the border gate of Aranyaprathet, SaKeo, Thailand to the point where the gunman was doing the action. The investigation also shows that after the birth of the second suspect, Mr. Pich Kimsrin, left Thailand immediately on the plane of Sky Angkor Airlines (Sky Angkor Airlines) to Phnom Penh at 9 pm on 7 January.

Concerning this story, the Commissioner of National Police, Mr. Sot Thet told Asia Free Radio on 9 January that the Cambodian side has not yet set a specific time to send the Thai suspect back to Thailand, while the second suspect is a Cambodian, Pich Kimsrin. The Cambodian police have not yet investigated the arrest.

Mr. S Thet: "Which side confirms which side is another matter, we are not sure yet who is involved with. Usually, when an incident happened somewhere, it is always a matter of collecting evidence, but that evidence is not 100% accurate, or what, we do not know. "Well, not just broadcasting, it's the truth.".

Thai police investigators found that the murder of Lim Kimya was systematically prepared by a gunman named Aekkalak Paenoi hired by a Cambodian territory commander. According to Thai authorities, the gunman received the first salary of nearly $1 thousand from Cambodia, and after that, the gunman withdrew about $ 600 to pay back the gun he had borrowed from. A police officer to go to the shooting and killing the victim.

Please see /09

# កសិករទទូចឱ្យលោក ហ៊ុន ម៉ាណែត ដោះស្រាយបញ្ហាតម្លៃស្រូវចុះថោក

ដកស្រង់ RFA

កសិករមួយចំនួនទទូចដល់លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ឲ្យដោះស្រាយបញ្ហាតម្លៃស្រូវចុះថោក ខណៈលោកបានជួបជាមួយសហព័ន្ធស្រូវអង្ករកម្ពុជា។

ការទទូចនេះ ធ្វើឡើងក្នុងពេលកសិករនៅក្នុងខេត្តមួយចំនួន កំពុងប្រឈមនឹងបញ្ហាស្រូវចុះថោកខ្លាំង ធ្វើឲ្យពួកគាត់ខាតបង់ប្រាក់ចំណូល និងគ្មានលទ្ធភាពសងបំណុលធនាគារ។

កសិករនៅស្រុកថ្មគោល ខេត្តបាត់ដំបង លោកស្រី ផាំង ណាម ប្រាប់វិទ្យុអាស៊ីសេរី នៅថ្ងៃទី៨ ខែមករា ថា លោកស្រីកំពុងប្រឈមនឹងបញ្ហាជីវភាព និងខាតបង់ប្រាក់ចំណូលច្រើន បន្ទាប់ពីស្រូវប្រភេទ នាងខុន នៅតំបន់នោះ ធ្លាក់ថ្លៃចុះដល់ ៥៨០ រៀលក្នុងមួយគីឡូក្រាម ។ លោកស្រី ថា តម្លៃស្រូវបែបនេះ ពុំអាចទូទាត់នឹងថ្លៃដើមបានឡើយ។

លោកស្រី ផាំង ណាម៖ «អីចឹងបានថា ដល់អីចឹងអត់រួចខ្លួនថ្លៃជី ថ្លៃថ្នាំ ថ្លៃច្រូត ដល់អីចឹងម្នាក់ៗនាំគ្នាត្រឹងអន្ទះសាដែរហ្នឹង ស្រូវវាធ្លាក់ថ្លៃពេក ហើយស្រូវវាចេះតែខ្ចង់ទៅហើយ តែបើច្រូតយកមកវាគ្មានកន្លែងដាក់វាចាល់អីចឹងទៅ ហើយបើលក់វាបានថោក»។

ស្រដៀងគ្នានេះ កសិករម្នាក់ទៀត នៅ ខេត្តកំពង់ឆ្នាំង លោកស្រី ជែម សុផារី ថ្លែងថា លោកស្រី នៅមិនទាន់ហ៊ានប្រមូលផលស្រូវនោះទេ បើទោះជាស្រូវដល់អាយុកាលត្រូវច្រូតកាត់ហើយក៏ដោយដោយសារតែស្រូវកំពុងចុះថោក។ លោកស្រីបន្ថែមថា បញ្ហាស្រូវចុះថោកនេះ នឹងក្លាយជា បន្ទុកមួយបន្ថែមទៀត ខណៈលោកស្រី គ្មានរបរអ្វីក្រៅពីធ្វើស្រែនោះឡើយ។

លោកស្រី ជែម សុផារី៖ «ចង់ឲ្យរាជរដ្ឋាភិបាលជួយស្រូវឲ្យបានមួយគីឡូមួយពាន់រៀលទៅ បើមិនបានអីក៏បានតម្លៃប៉ុណ្ណឹងទៅ ប្រជាពលរដ្ឋថ្លៃជំពាក់គេ ជំពាក់អីវាកាត់បន្ថយខ្លះទៅ តែបើអត់បានប៉ុណ្ណឹងទេ គឺផាត់ទូទាត់មិនរួចតែម្ដង»។

ការត្អូញត្អែររបស់កសិករនេះ ធ្វើឡើងក្នុងពេលតម្លៃស្រូវនៅតាមបណ្ដាខេត្តមួយចំនួនដូចជាបាត់ដំបងបន្ទាយមានជ័យ សៀមរាប និងកំពង់ឆ្នាំងជាដើម កំពុងធ្លាក់ថ្លៃជាបន្តបន្ទាប់នៅប៉ុន្មានថ្ងៃចុងក្រោយនេះ។



សហព័ន្ធស្រូវអង្ករកម្ពុជា ឲ្យដឹងថា កាលពីថ្ងៃទី៣ ខែមករា តម្លៃស្រូវប្រភេទ អូអឹម (OM 54.51) នៅតាមបណ្ដាខេត្តមួយចំនួនដូចជាបាត់ដំបងបន្ទាយមានជ័យ និងពោធិ៍សាត់ជាដើម មានតម្លៃចន្លោះពី ៩៣០ ដល់ ៩៧០ រៀលក្នុងមួយគីឡូក្រាម តែតម្លៃនេះ បានធ្លាក់ចុះនៅសល់ចន្លោះពី ៧៩០ ដល់ ៨១០ រៀល កាលពីថ្ងៃទី៦ ខែមករា ។ ចំណែកឯស្រូវប្រភេទ អ៊ីអ៊ែ កាលពីថ្ងៃទី ៣ ខែមករា មានតម្លៃ ៨៧០ រៀលក្នុងមួយគីឡូក្រាម តែនៅត្រឹម ៧១០ រៀលក្នុងមួយគីឡូក្រាមកាលពីថ្ងៃទី ៦ ខែមករា ហើយស្រូវប្រភេទនេះ ពលរដ្ឋនៅខេត្តបាត់ដំបង ឲ្យដឹងថា បានបន្តធ្លាក់ថ្លៃនៅត្រឹម ៥៨០ រៀលក្នុងមួយគីឡូក្រាម នៅថ្ងៃទី៨ ខែមករា។

ស្របពេលពលរដ្ឋត្អូញត្អែរមិនដាច់ពីមាត់អំពីតម្លៃស្រូវចុះថោក នាយករដ្ឋមន្ត្រី លោក ហ៊ុន ម៉ាណែត នៅព្រឹកថ្ងៃទី៨ ខែមករា បានបង្ហោះសារនៅលើហ្វេសប៊ុក ដែលបង្ហាញពីសកម្មភាពរបស់លោកអនុញ្ញាតឲ្យតំណាងសហព័ន្ធស្រូវអង្ករកម្ពុជា ជួបសម្ដែងការគួរសម និងពិភាក្សាការងារ ។ ជំនួបនេះ មានការចូលរួមពីរដ្ឋមន្ត្រីក្រសួង និងស្ថាប័នពាក់ព័ន្ធនឹងវិស័យស្រូវអង្ករដូចជា ក្រសួងកសិកម្ម ក្រសួងពាណិជ្ជកម្ម អគ្គនាយក

តទៅទំព័រទី១០

# Farmers ask Hun Manet to solve the problem of wheat prices

By RFA

A small number of farmers asked Prime Minister Hun Manet to solve the problem of low grain prices while he met with the Rice Federation of Cambodia.

The cut comes as farmers in some provinces are facing severe wheat depletion, making them lose income and unable to repay bank loans.

A farmer in Thomkol district, Battambang province, Mrs. Phang Nam told Radio Asia Free on January 8 that she is facing livelihood problems and losing a lot of income after the price of Neang Khun wheat in that area fell to 580 Riel per kilogram. Mrs. said that the price of grain like this cannot be paid with the original price.

Mrs. Phang Nam: «What is this? Why is it that you are not ready for the cost of fertilizers, medicines, and the harvest? Everyone is anxious. The price of wheat is too expensive. The wheat is always stale. But if the harvest is brought, there is no place to put it. What is this? Sell it for cheap".

Similarly, another farmer in Kampong Chhnang province, Mrs. Jem Sophary said that she has not yet dare to harvest wheat even though the wheat is old enough to be harvested and because the wheat is decreasing. She added that the problem of wheat decreasing will be another burden since she has nothing to do except farming.

Mrs. James Sophari: «Want the government to help the wheat to get one thousand riels per kilogram, if it doesn't get anything like this, the people owe, it will reduce the amount of debt, but if it's not enough, it will not be paid at all».

This farmer's complaint is made when the price of wheat in some provinces such as Battambang, Banteay Meanchey, Siem Reap and Kampong Chhnang, etc. are continuously falling in the last few days.

Cambodia Rice Federation informs that since January 3, the price of OM wheat (OM 54.51) in some provinces such as Battambang, Banteay Meanchey and Pursat, etc. have been priced from 930 to 970 riels per kilogram, but the price has fallen to 790 to 810. Real since January 6. While the EE type wheat on January 3 was priced at 870 Riel per kg, but it remained only 710 Riel per kg on January 6, and the citizens of Battambang province informed that the price continued to fall to 580 Riel per kilogram on the day. January 8th.

While the citizens are complaining non-stop about the low price of wheat, Prime Minister Hun Manet posted a message on Facebook on the morning of January 8th showing his actions that allowed the representatives of the Cambodian Rice Federation to meet and discuss the work. This meeting has participation from ministers and organizations related to rice sector, such as the Ministry of Agriculture, Ministry of Commerce, Tax Department and Department of Koy and the Prime Minister of Cambodia. But he did not reveal the outcome of the meeting.

Concerning this issue, the press is close to the government of Freshnews (Freshnews) informs that the meeting between Mr. Hun Manet and the representatives of the Cambodia Rice Federation is to discuss investment and trade in rice in Cambodia.

Free Asia Radio has not yet been able to contact the spokesperson of the Ministry of Agriculture Ms. M. Rachana and the spokespokesman of the Prime Minister Mr. Meas Sophon to ask for answers on this issue. It is still on January 8.

Meanwhile, the Secretary General of Cambodia's Rice Federation, Mr. Lon Yeng told Asia Free via Telegram that he will give this information tomorrow.

The Board of Directors of the Cambodia Farmers Solidarity Organization, Mr. Dy Kuntha said that the government should strengthen the implementation of the existing policies

Please see /10

តមកពីទំព័រទី ០៧

# សោកនាថកម្មលើរូប លឹម គឹមយ៉ា

មិនដែលដាច់រហូតដល់ខ្មែរមានចលនា រំដោះនៅទល់ដែនខ្មែរថៃមួយ ដឹកនាំ ដោយលោក សឺង សាន(អតីតនាយក រដ្ឋមន្ត្រី)នឹងឧត្តមសេនីយ ដៀន ដែល... ប៉ុន្តែក្រុមព្រឹទ្ធាចារ្យទាំងនោះបានរំសាយ ខ្លួនចោលទៅវិញ ដោយសារតែក្រុម លោក សឺង សាន បានចូលរួមរំដោះ ជាមួយចលនាត្រីភាគី ដែលក្នុងនោះ មានភាគីមួយជាក្រុមខ្មែរក្រហមកុម្មុយនីស្ត ប៉ុល ពត។ លោក លឹម គឹមយ៉ា នៅបន្ត ផ្សព្វផ្សាយ «ព្រឹត្តប័ត្រមូលខ្មែរ»ជាច្រើន ឆ្នាំបន្តរមក បើទោះជាលោក ស៊ឹម វ៉ា បានបាត់បង់ជីវិតទៅហើយក្តី។ លោក ជាមនុស្សសាមញ្ញ សុចរិត ជាទីរាប់អាន គ្រប់មិត្តសម្លាញ់ ឈឺឆ្អាលនឹងជាតិសាស្ត្រ ខ្មែរ ហ៊ានបង្ហាញឆន្ទៈខ្លួនដោយមិនដែល ខ្លាចរអា និយាយតិចតែច្បាស់លាស់ មិនធ្វើឲ្យគេសង្ស័យឡើយ ទោះជា មកដល់សព្វថ្ងៃនេះក៏ដោយ។

ការចូលសភាខ្មែរ នៅឆ្នាំ២០១៣ បន្ទាប់ពីចូលនិវត្តន៍នៅស្រុកបារាំងមក គឺជាបំណងដ៏មោះមុតក្នុងការជួយស្រោចស្រង់ ប្រជាជាតិឲ្យរួចចាកពីអំណាចផ្តាច់ការ ឲ្យទទួលបាននូវអភិវឌ្ឍន៍ដូចបរទេស សេរីឯទៀតៗ តែលោកប្រឈមមុខ នឹង គ្រោះថ្នាក់ផ្ទាល់ខ្លួន ជាមួយមិត្រភ័ក្រ្ត នយោបាយនៃបក្សសង្គ្រោះជាតិឯទៀត ដោយមិនតក់ស្លុត នឹងបរិយាកាសហឹង្សាយ៉ាងពេញទំហ៊ឹង ពិអតីតមេដឹកនាំ របបកុម្មុយនីស្តដែលកំពុងតែកាន់អំណាច នៅកម្ពុជា។ ជាបន្តរបន្ទាប់ទៅទៀត ទាំង គណបក្សសង្គ្រោះជាតិត្រូវរំលាយចោល ក៏ដោយក្តី លឹម គឹមយ៉ា ក៏មិនបានបញ្ឈប់ ខ្លួនពីការបញ្ចេញយោបល់ ទិទានចំពោះ អ្វីដែលលោកយល់ថា«មិនគប្បីចំពោះ ប្រទេសនឹងពលរដ្ឋខ្មែរ ជារៀងរាល់ពេល ជាមួយនឹង«លិខិតខ្លីៗពណ៌លឿង»របស់ លោក តែដដែល។ លោក លឹម គឹមយ៉ា ជាមនុស្សដែលមានលក្ខណៈសម្បត្ត មិនដែលប្រាថ្នាបុណ្យសក្តិឬកិត្តិយស ខ្ពង់ខ្ពស់ អ្វីនោះទេ តែលោកស្វែងរក កម្លាំងមកជួយប្រជាពលរដ្ឋខ្មែរ ដែល ពេលនោះ មានតែគណបក្សសង្គ្រោះ ជាតិតែ១គត់ ដែលបង្ហាញខ្លួនជាគណ បក្សប្រជាធិបតេយ្យ គោរពសិទ្ធិមនុស្ស នឹងជាកន្លែងរួបរួមផ្តុំអ្នកស្នេហាជាតិ មក ធ្វើសកម្មភាពដើម្បីជាប្រយោជន៍ដល់ ជាតិបាន ប៉ុន្តែការប្រឆាំងដ៏លេចធ្លោ របស់លោក ក៏បណ្តាលឲ្យលោក ក្លាយជា«ផ្លាំងស៊ីប»ដ៏សំខាន់ របស់របប ដែលចូលចិត្តឈាមជាដំណោះស្រាយ។

ករណីឃាដកម្មនោះនឹងទៅជា យ៉ាងណា? នៅថ្ងៃទី១៥នេះ ប៉ូលីសថៃ បានរកឃើញនឹងតាមចាប់ជនសង្ស័យ ថ្មីទៀត ដែលជាអ្នកវេរលុយច្រើនម៉ឺន បាត ច្រើនដងទៅឲ្យជនដៃដល់ ។ គេ ដឹងថា អ្នកវេរលុយនោះ ជាជនសង្ស័យ ទី២ជាជនជាតិខ្មែរ គឺជាបច្ចុប្បន្នទីប្រឹក្សា របស់លោក អតីតនាយករដ្ឋមន្ត្រី ដែល មិនទាន់ដកខ្លួនពីអំណាចបាន រីឯ



ពិធីបុណ្យសពព៧ថ្ងៃលោក លឹម គឹមយ៉ា នៅវត្តពោធិវង្ស




រូបភាពកាមេរ៉ាខ្មាំងកាំភ្លើងជិះម៉ូតូរត់គេចខ្លួនក្រោយការបាញ់សម្លាប់លោក លឹម គឹមយ៉ា ភ្លាមៗ

ជនសង្ស័យទី១វិញ ក៏ជាប្អូនបង្កើតរបស់ មន្ត្រីជាទីប្រឹក្សារបស់លោក ហ៊ុន សែន ដែរគឺលោកពេជ្រ ស្រស់ម្នាក់ក្រោយនេះ ធ្លាប់ជាមេដើមបណ្តឹងធ្វើឲ្យមានការ រំលាយគណបក្សសង្គ្រោះជាតិចោល។ ប៉ូលីសថៃមិនទាន់មានសហការពិតប្រាកដ ពីរដ្ឋាភិបាលខ្មែរទេ ដែលជាហេតុធ្វើឲ្យ គេយល់ថា ជាឃាដកម្មនយោបាយ ទំនងជាមានខ្សែរទាក់ទងដោយចំពោះ ទៅថ្នាក់ដឹកនាំជាន់ខ្ពស់ នៃប្រទេស កម្ពុជាផង។

នៅប៉ារីស ក្រុមមិត្តភក្រ្តនឹងសមាជិក បក្សសង្គ្រោះជាតិ មានសេចក្តីសោក ស្តាយចំពោះការបាត់បង់ជិវិតលោក លឹម គឹមយ៉ា បាននាំគ្នាចូលរួមមរណទុក្ខ ជាមួយគ្រួសារ លឹម គឹមយ៉ា នឹងធ្វើបុណ្យ គម្រប់៧ថ្ងៃ ឧទ្ទិសកុសលជូនសព តាម គន្លងព្រះពុទ្ធសាសនា នៅវត្តពោធិវង្ស។ រីឯនៅទីក្រុងឡុងប៊ីច នៃសហរដ្ឋអាមេរីកវិញ ក៏សមាគមខ្មែរនៅទីនោះក៏ប្រារព្ធ ការគោរពវិញ្ញាណក្ខន្ធដូចគ្នា, ហើយ ទំនងជាមានធ្វើពិធីរំលឹកការបាត់បង់ ជីវិតលោក លឹម គឹមយ៉ា នៅច្រើនកន្លែង ទៀត ដែលធ្វើឲ្យការស្លាប់នេះ មានទំហំជា«វិរបុរសខ្មែរ» ហើយក៏ធ្វើឲ្យ សាធារណជននឹកទៅដល់«វិរបុរស ក្លាហាន»ម្នាក់ទៀតគឺលោកបណ្ឌិត កឹម ឡី ដែលបានបានបង់ជិវិត ដោយការ បាញ់សម្លាប់ដែរ កាលពីពេលមុននោះ មិនអាចឲ្យកូនខ្មែរ បំភ្លេចនូអំពើបំផ្លាញ ធនធានបញ្ញាវន្តរបស់ខ្មែរ បានឡើយ ៕

# Thai police investigates that the murder case of Lim Kimya is systematically prepared by the head of Cambodia

From Page 07

Thai police suspect that this cross-border murder case is planned to be held in advance by commanders or conspirators, sending funds, trackers and pointing out the identity of the suspected victim as Mr. Pich Kimsrin and another stage is There are people who are waiting to release gunmen from Thailand, those who cross the Cambodia border through the gate illegally and those who escapes to Battambang province.

Regarding this, law and democratic governance student Mr. Von Chanlot said that according to the Cambodian legal procedure, the extradition of the second suspect, who is a Khmer citizen, involved in the murder of Mr. Lim Kimya, to Thailand, can be done only if Thai authorities do. Provide sufficient evidence and have approval from Cambodia government.

Mr. Von Chanlot: «In summary, the case that Thai authorities have issued the case, also indicates that other stakeholders have Khmer citizenship, although they cannot make a way to Thailand due to the obstacles of the citizenship, but this person cannot escape from the law of committing murder. Not on the opposition politicians. Therefore, must be punished according to Cambodian law.

Also involved in the murder case of Lim Kimya. After the death of her husband on January 9, the wife of Lim Kimya, who is a French citizen and his brother, came to Thai police officers to make a diary and prepare documents to receive her husband's body by request. To have a certificate from the Embassy of Cambodia and French Embassy. During the interval, the wife of Mr. Lim Kimya visited her husband's body which was kept in Vajira Hospital in Bangkok, Thailand.

Photo captions and diagram shows the location of Lim Kimya, a victim and a suspect who were on a bus together on January 7, 2025. In the second picture, the suspect got off the last bus. PHOTOS: AMARA TV



តមកពីទំព័រទី ១១

# កសិករទទូចឲ្យលោក ហ៊ុន ម៉ាណែត

ដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាជាដើម ។ ប៉ុន្តែលោក ពុំបានបង្ហាញពីលទ្ធផល នៃការកិច្ចប្រជុំនេះឡើយ។

ទាក់ទិននឹងបញ្ហានេះ សារព័ត៌មានស្និទ្ធនឹងរដ្ឋាភិបាល ហ្រ្វេសញូ (Fresh_news) ឲ្យដឹងថា ជំនួបរវាងលោក ហ៊ុន ម៉ាណែត និងតំណាងសហព័ន្ធស្រូវអង្ករកម្ពុជា គឺធ្វើឡើង ដើម្បីជជែកអំពីការវិនិយោគ និងការធ្វើពាណិជ្ជកម្មស្រូវអង្ករនៅកម្ពុជា។

វិទ្យុអាស៊ីសេរី នៅមិនទាន់អាចទាក់ទងអ្នកនាំពាក្យក្រសួងកសិកម្ម កញ្ញា អ៊ឹម រចនា និងអ្នកនាំពាក្យនាយករដ្ឋមន្ត្រី លោក មាស សុភណ្ឌ ដើម្បីសុំការឆ្លើយតបជុំវិញបញ្ហានេះបាននៅឡើយទេ នៅថ្ងៃទី៨ ខែមករា។

ចំណែកឯ អគ្គលេខាធិការ សហព័ន្ធស្រូវអង្ករកម្ពុជា លោក លន់ យ៉េង ប្រាប់អាស៊ីសេរីតាមបណ្ដាញសង្គមតេលេក្រាម (Telegram) ថា លោកនឹងផ្ដល់ព័ត៌មាននេះ នៅថ្ងៃស្អែក។

ក្រុមប្រឹក្សាភិបាលនៃអង្គការសាមគ្គីភាពកសិករកម្ពុជា លោក ឌី គន្ធា មានប្រសាសន៍ថា រដ្ឋាភិបាល គួរតែពង្រឹងអនុវត្តគោលនយោបាយ ដែលមានស្រាប់ពាក់ព័ន្ធនឹងផលិតកម្មស្រូវ-អង្ករ ដើម្បីធានាថា ទិន្នផលកសិករអាចលក់បានក្នុងតម្លៃសមរម្យ និងអាចទទួលយកបាន។

លោក ឌី គន្ធា៖ «រដ្ឋាភិបាលរបស់គេក៏គេយកចិត្តទុកដាក់លើគោលនយោបាយលើកកម្ពស់ផលិតកម្ម តាមកិច្ចសន្យា ដោយធានានូវការចរចាតម្លៃសមរម្យ ដែលធៀបទៅនឹងការវិនិយោគរបស់កសិករ ដោយធានាថា កសិករក្រោយពីប្រមូលផលហើយ គឺអាចទទួលបានផលកម្រៃសម្រាប់យកទៅទូទាត់សងបំណុល ឬក៏បានចំណូលមកមកសម្រាប់ដោះស្រាយក្នុងគ្រួសារ ដោយមិនធ្វើឲ្យកសិកររបស់ពួកគេ ប្រឈមមុខនឹងបំណុលវណ្ឌក ឬក៏កូនចៅរបស់ពួកគេចំណាកស្រុក ទៅធ្វើចំណាកស្រុកទៅឯនាយសមុទ្រនោះទេ»។

ស្ទើរតែជារៀងរាល់ឆ្នាំ កសិករតែងតែត្អូញត្អែរពីតម្លៃស្រូវចុះថោក ខណៈដំណាំស្រូវរបស់ពួកគាត់ ក៏តែងជួបគ្រោះរាំងស្ងួត និងគ្មានប្រព័ន្ធទឹកស្រោចស្រពនៅរដូវប្រាំង និងជួបគ្រោះទឹកជំនន់ នៅរដូវវស្សា ។ បញ្ហាទាំងនេះ បានធ្វើឲ្យកសិករជាច្រើន ខាតបង់ប្រាក់ចំណូល និងប្រឈមនឹងបញ្ហាជំពាក់បំណុលវណ្ឌក ហើយពួកគាត់ បានស្នើដល់អាជ្ញាធរពាក់ព័ន្ធ ឲ្យជួយស្វែងរកទីផ្សារស្រូវអង្ករជូនពួកគាត់ ។ កន្លងទៅ អាជ្ញាធរអះអាងថាកត្តាស្រូវចុះថោកគឺដោយសារតែកសិករសម្រុកច្រូតក្នុងពេលតែមួយ ឬក្នុងពេលប្រទេសជិតខាងកំពុងប្រមូលផលស្រូវដូចគ្នានឹងកម្ពុជា។

ទោះជាយ៉ាងណា កសិករទទូចដល់រដ្ឋាភិបាល ឲ្យជួយអន្តរាគមន៍ ស្វែងរកទីផ្សារស្រូវអង្ករសម្រាប់ពួកគាត់ ដើម្បីកាត់បន្ថយផលប៉ះពាល់បណ្ដាលមកពីស្រូវចុះថោក ធ្វើឲ្យពលរដ្ឋជំពាក់បំណុលធនាគារដោះខ្លួនមិនរួច៕

# Farmers ask Hun Manet to solve the problem of wheat prices

From Page 08

related to wheat-rice production to ensure that farmers' produce can be sold at a reasonable price and acceptable price.

Mr. Dy Kuntha: «His government also cares about the policy of promoting contract production by ensuring fair price negotiation compared to farmers' investment, ensuring that farmers after harvest can get the revenue to pay off their loans or else. "Income comes to settle families, without putting their farmers in debt, or their descendants migrate to the sea.".

Almost every year, farmers always complain about the low price of wheat, while their crops also face drought and lack irrigation system during dry season and flood during rainy season. These problems have caused many farmers to lose income and face warehouse debt, and they have asked the authorities to help find the market for rice for them. In the past, the authorities claimed that the factor of wheat decreasing is because the farmers harvesting at the same time or when neighboring countries are harvesting the same wheat as Cambodia.




# អ្នកឃ្លាំមើលចាត់ទុកការចាប់ខ្លួនអតីតឧកញ៉ា ហេង សិទ្ធី គឺជាករណីពាលស៊ីពាល

ដកស្រង់ពីCambodia Daily

អ្នកឃ្លាំមើលស្ថានការណ៍កម្ពុជាលើកឡើងថា ករណីចាប់ខ្លួនអតីតអ្នកឧកញ៉ា ហេងសិទ្ធី មិនមែនជាការអនុវត្តច្បាប់ចាប់អ្នកប្រព្រឹត្តខុសទេ គឺជាករណីពាលស៊ីពាលប៉ុណ្ណោះ។

ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា លោក ម៉ែនណាត ប្រាប់សារព័ត៌មាន The Cambodia Daily នៅថ្ងៃទី១៦ មករា នេះថា ជារឿងអកុសលបំផុតដែលលោក ហេង សិទ្ធី ត្រូវបានចាប់ខ្លួន ហើយគ្រោងបញ្ជូនទៅប្រទេសកម្ពុជាដើម្បីកាត់ទោសទៅតាមច្បាប់នៃរដ្ឋាភិបាលត្រកូលហ៊ុនស្របពេលដែលមនុស្សជាប់ពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋដែលលោក ហេង សិទ្ធី បានទម្លាយ នៅតែគ្មានការស៊ើបអង្កេតពីរដ្ឋាភិបាលគ្រួសារមួយនេះ។

លោក ម៉ែន ណាត លើកឡើងថា ដើម្បីភាពយុត្តិធម៌ក្នុងរឿងនេះ ក្រៅពីការចាប់ខ្លួនលោក ហេង សិទ្ធី ដែលរងការចោទប្រកាន់ពីបទគំរាមកំហែងហែកកេរ្តិ៍រដ្ឋាភិបាលក៏ត្រូវបើកការស៊ើបអង្កេតលើមន្ត្រីរបស់ខ្លួនដែលលោក ហេង សិទ្ធី បានទម្លាយផងដែរ ដូចជា លោក #ស ថេត លោក ស សុខា លោក #គួចចំរើន និងលោក សុខផល រួមទាំងមន្ត្រីនគរបាលព្រហ្មទណ្ឌ និងជាពិសេសអ្នកឧកញ៉ាហ៊ុនតូ។



ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជារូបនេះបញ្ជាក់ថា បើគ្រាន់តែចាប់ខ្លួនលោក ហេង សិទ្ធី ដើម្បីកាត់ទោសដោយគ្មានការស៊ើបអង្កេតលើអ្នកដែលលោក ហេង សិទ្ធី បានអះអាងថាជាអ្នកនៅពីក្រោយក្រុមឧក្រិដ្ឋជនទេនោះរដ្ឋាភិបាលត្រកូលហ៊ុនអាចត្រឹមតែកម្ចាត់បន្លាចេញពីកែវភ្នែករបស់ខ្លួនប៉ុណ្ណោះ ប៉ុន្តែរបួសមួយនេះនឹងមិនអាចព្យាបាលជាសះស្បើយបានឡើយ។

កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៥ អគ្គស្នងការនគរបាលជាតិ លោក ស ថេត អះអាងថាអតីតឧកញ៉ា ហេង សិទ្ធី ពិតជាត្រូវបានចាប់ខ្លួននៅព្រំដែនប្រទេសរុស្ស៊ី ប្រាកដមែន តែមិនទាន់ត្រូវបានបញ្ជូនទៅប្រទេសកម្ពុជាវិញទេ។

លោកថា ក្រសួងយុត្តិធម៌ និងក្រសួងការបរទេសកម្ពុជា កំពុងដំណើរការបំពេញបែបបទផ្ញើបត្យាប័នទៅកាន់អគ្គព្រះរាជអាជ្ញានៃប្រទេសរុស្ស៊ី បន្ទាប់ពីរុស្ស៊ី តម្រូវឱ្យកម្ពុជាបំពេញបែបបទ និងឯកសារនានាដើម្បីបញ្ជូនខ្លួនអតីតឧកញ៉ារូបនេះទៅប្រទេសកម្ពុជាវិញ។

លោក ស ថេត បញ្ជាក់ថា រដ្ឋាភិបាលមិនទាន់កំណត់ពេលវេលាច្បាស់លាស់ណាមួយថានឹងត្រូវបញ្ជូនអតីតឧកញ៉ា ហេង សិទ្ធី ទៅកម្ពុជាក្នុងពេលណាមួយពិតប្រាកដនៅឡើយទេ ប៉ុន្តែសំណុំឯកសារពាក់ព័ន្ធដែលអគ្គព្រះរាជអាជ្ញារុស្ស៊ី ត្រូវការ ភាគីកម្ពុជាបានបញ្ជូនទៅអស់ហើយ គឺរង់ចាំតែការសម្រេចចុងក្រោយពីភាគីរុស្ស៊ី តែប៉ុណ្ណោះ។ កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ក្រសួងមហាផ្ទៃ បានប្រកាសស្តីពីការប្រកាសមោឃភាពលិខិតឆ្លងដែនរបស់អតីតឧកញ៉ា ហេង សិទ្ធី បន្ទាប់ពីសាលាដំបូងរាជធានីភ្នំពេញបានចេញដីកាបង្គាប់ឱ្យចាប់ខ្លួនអតីតឧកញ៉ារូបនេះកាលពីដើមខែធ្នូ ឆ្នាំ២០២៤ ពីបទគំរាមកំហែងហែកកេរ្តិ៍មានស្ថានទម្ងន់ទោស៕







ទំព័រកំសាន្ត

# ដំណើរ«ថៅដក»យកឈ្នះលើ២៤ម៉ោងក្នុងមួយថ្ងៃ

រាត្រីទី២១ខែធ្នូ២០២៤ សមាគមខ្មែរ«អាគីរ»នៅទីក្រុងរ៉ែន ប្រទេសបារាំង គេនាំគ្នាប្រារព្ធពីធីបុណ្យយ៉ាងគ្រឹកគគ្រេង តាំងពីម៉ោងពីម៉ោង១០ព្រឹក រហូតដល់អាធ្រាត។ ទាំងក្មេងទាំងចាស់ខ្មែរ ក្នុងតំបន់អ៊ីលអេវិឡែន ក្នុងសំលៀកបំពាក់ស្រស់ស្អាត គួរឲ្យស្រឡាញ់គ្រប់ៗគ្នា បានមកចូលរួម ម្នាក់ៗមានយួរទាំងម្ហូបអាហារប្រណិតៗ តាំងពីព្រឹក មកប្រគេនចង្ហាន់ព្រះសង្ឃក្នុង«បុណ្យផ្កា»ផង ដើម្បីប្រមូលបច្ច័យឧបត្ថម្ភសាលាសិក្សាកុមារខ្មែរ នឹងមកចូលរួមពិធី«ដើមស្រល់ណូអែល»នៅពេលព្រលប់ ក៏ដើម្បីជូនជារង្វាន់ដល់សមាជិកសមាជីកា ចំពោះការខិតខំប្រឹងប្រែងប្រចាំឆ្នាំ២០២៤ យ៉ាងសប្បាយរីករាយផង។

ក៏ប៉ុន្តែនៅពេល«ប៉ាៗណូអែល»បានចែកអំណោយរួច ក៏ត្រឡប់ទៅប៉ូលខាងជើងវិញ «ថៅដក»ជាសមាជីកម្នាក់នៅក្នុងចំណោមបរិស័ទទាំងឡាយ ក៏ប្រកាសសួរថា តើទាំងអស់គ្នាហ៊ានភ្នាល់ជាមួយនឹងខ្ញុំទេថា«ខ្ញុំអាចនឹងយកឈ្នះពេល២៤ម៉ោងក្នុងមួយថ្ងៃបាន»...គ្មាននរណាម្នាក់អាចជឿ«ថៅដក»បានទេ ដោយសារតែតាំងពីណាពីណីមក ពេលម៉ោងមានតែ២៤ម៉ោងក្នុង១ថ្ងៃតែប៉ុណ្ណោះ មិនដែលលើសទេ ដូច្នេះការភ្នាល់នេះជាការអាចស្រួលនឹងយកឈ្នះលើ«ថៅដក»ណាស់។ តែហេតុអ្វីក៏«ថៅដក»ហ៊ានភ្នាល់គ្នា ដ៏គ្មានសង្ស័មថាអាចយកឈ្នះបានយ៉ាងនេះ? ដូច្នោះហើយអ្នកដែលធ្លាប់ស្គាល់«ថៅដក»ថាជាអ្នក«ហ៊ាននិយាយហ៊ានធ្វើ» ក៏ជូនពរថា«សូមអ្នកធ្វើទៅ ឲ្យបានជោកជ័យ» រីឯអ្នកដែលធ្លាប់លំបាក មិនជឿលើគំនិតហួសហេតុ ក៏ជូនពរដែរថា«បើធ្វើមិនបានសម្រេច ក៏សុំឲ្យបានត្រឡប់មកវិញណា!»...។

ម៉ោង១០យប់ថ្ងៃទី២០ខែធ្នូឆ្នាំ២០២៤ នៅយប់នោះតែម្ដង «ថៅដក»សន្យាថា«ខ្ញុំនឹងប្ដើមធ្វើកិច្ចការមួយ ចាប់ពីម៉ោង១០យប់ នៃថ្ងៃទី២១នេះទៅ ដែលជាថ្ងៃបុណ្យរបស់អ្នកទាំងអស់គ្នា នៅអាគីរថា ខ្ញុំនឹងចេញដំណើរពីទីប្រជុំគ្នានេះ ទៅកាន់ទិដ៏ឆ្ងាយមួយ ដែលខ្ញុំនឹងប្រើពេល ពីម៉ោង១២នៃពាក់កណ្ដាល



ពែរណូអែលចុះមកជួបសមាគមខ្មែរនៅរ៉ែន



ធ្វើបុណ្យផ្កាជួយថ្នាក់សិក្សាអាគីរ

តទៅទំព័រទី១៩


## The Lowell Regional Transit Authority

Announces




**A Temporary Fare Free Pilot Program Commencing**

**December 1, 2024**

**And Continues Through September 30, 2025**

(Fares may resume 10/1/2025 Subject to State Funding)

The LRTA wants to Thank Governor Maura Healey and Lieutenant Governor Kim Driscoll, as well as the Massachusetts State Legislature for funding this Fare Free Transportation Pilot Program that will greatly benefit our communities.

Lowell Regional Transit Authority

LRTA.com

# អ្នកជំនួញជនជាតិចិនម្នាក់ប្តឹងអ្នកឧកញ៉ា ហ៊ុន តូ ករណីបោកប្រាស់លុយ៩លានដុល្លារ និងប៉ុនប៉ងចាប់ជំរិត

ដកស្រង់ពីCambodia Daily
ផ្សាយថ្ងៃទី០៧ ខែ០១ ឆ្នាំ២០២៥

អ្នកជំនួញជនជាតិប៉េកាំង ប្តឹងក្មួយប្រុសលោក ហ៊ុនសែន គឺអ្នកឧកញ៉ា ហ៊ុនតូ ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លោក កើត រិទ្ធ ពីបទរំលោភសេចក្តីទុកចិត្តក្នុងអំពើបោកប្រាស់លុយចំនួន ៩លានដុល្លារអាមេរិក និងប៉ុនប៉ងចាប់ជំរិត។

អ្នកជំនួញជនជាតិចិនម្នាក់ឈ្មោះ SUN RUIFENG ដែលមានដើមកំណើតក្នុងទីក្រុងប៉េកាំង ប្រទេសចិន បានដាក់ពាក្យបណ្តឹងមួយទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លោក កើត រិទ្ធ កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០២៥ ថា លោក ហ៊ុន តូ បានបោកប្រាស់លុយចំនួន ៩លានដុល្លារអាមេរិកជាលុយសុទ្ធពីរូបគេ ជាថ្នូរនឹងការរត់ការស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មរ៉ែមាសនៅខេត្តមណ្ឌលគិរី។

អ្នកជំនួញជនជាតិចិនរូបនេះអះអាងថា ក្រៅពីលុយ ៩លានដុល្លារនេះ លោក ហ៊ុន តូ ក៏បានយកលុយពីខ្លួនចំនួន ១៤ លានដុល្លារអាមេរិក ក្នុងនោះ ៧លានដុល្លារសម្រាប់សេវារត់ការសុំសិទ្ធិអាជីវកម្ម



ហ៊ុន តូ ក្មួយលោក ហ៊ុន សែន(រូបកណ្តាល) ឆបោកជនបរទេស

និងលុយ ៧លានដុល្លារទៀតសម្រាប់

តទៅទំព័រទី១៨

# A Beijing businessman has sued Hun Sen's nephew, Tycoon Hun To, to Justice Minister Keut Rith for breach of trust in a $ 9 million fraud and attempted kidnapping.

**Quote from Cambodia Daily**
**Posted on January 07, 2025**

A Chinese businessman named SUN RUIFENG, originally from Beijing, China, filed a complaint with Justice Minister Keut Rith on January 5, 2025 against Hun To for swindling of $ 9 million in cash from him in exchange for running for a gold mining license in Mondulkiri province.

The Chinese businessman claims that in addition to the $ 9 million, Hun To also took $ 14 million from him, including $ 7 million for business licensing services and $ 7 million for leadership (top leader). But after receiving all the money, Hun To not only did not fulfill his promise, but also sent a gang of kidnappers, but he escaped from Cambodia for safety in time.

SUN RUIFENG, a Chinese national, stated that as a foreign investor, he loves and sees investment opportunities in Cambodia and wishes to participate in development through this investment, but unfortunately, he was cheated by Mr. Hun To instead.

The Chinese businessman states that he spent a lot of money on Hun To, such as spending on gifts, expensive brand watches and expensive wines.


យើងជឿថា ឆ្នាំល្អបំផុតរបស់អ្នកមកដល់ហើយ
(ឆ្នាំកន្លងទៅ ក៏ល្អសម្រាប់អ្នកដែរ)



Element Care PACE ជួយអ្នកឱ្យរស់នៅដោយឯករាជ្យនៅក្នុងសហគមន៍។

- ការថែទាំសុខភាពតាមបែបវេជ្ជសាស្ត្រ ថែទាំធ្មេញ និងថែទាំភ្នែកផ្ទាល់ខ្លួន ។
- មជ្ឈមណ្ឌលបើកបម្រើនៅពេលថ្ងៃ
  មានការដឹកជញ្ជូន មានអាហារ និងសកម្មភាពសង្គម
  ទាំងអស់នេះ អ្នកក៏អាចរក្សាសុខភាពល្អបំផុត។

Element Care | PACE

ស្វែងយល់បន្ថែម តើអ្នកឬមនុស្សជាទីស្រឡាញ់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែរឬទេ៖
(877) 803-5564 (TTY 711) ElementCare.org

មិនគិតថ្លៃសម្រាប់អ្នកមានសិទ្ធិទទួលបាន MassHealth និង Medicare ។ សូមទាក់ទងមកយើងសម្រាប់តែ Medicare និងជម្រើសបង់ប្រាក់ដោយខ្លួនឯង។

អ្នកចូលរួមទទួលបានការថែទាំសុខភាពទាំងអស់ សេវាពេទ្យឯកទេស - និងសេវាសង្គ្រោះបន្ទាន់ផ្សេងទៀត ដែលអនុញ្ញាតដោយ PACE ឬទទួលខុសត្រូវទាំងស្រុង និងផ្ទាល់ខ្លួនចំពោះថ្លៃសេវាដែលគ្មានការអនុញ្ញាត។



ROSA & TAING LAW, LLC





Attorney Francisco J. Rosa
មេធាវី ហ្វ្រានស៊ីសស្កូ ជេ. រ៉ូសា

Concentrated in
Auto Accident
Personal Injury
Real Estate Closing
Immigration
Divorces
Child Custody
Bankruptcy

Attorney Andrew 'Bunna' Taing
មេធាវី អេនឌ្រូ ប៊ុណ្ណា តាំង

ជំនាញខាងផ្នែក៖
គ្រោះថ្នាក់រថយន្តគ្រប់ប្រភេទ
ការរងរបួសផ្ទាល់ខ្លួន
ការកាត់ឈ្មោះប្តូរផ្ទះ
អន្តោប្រវេសន៍
ការលែងលះ
ការគ្រប់គ្រងថែរក្សាកូន
ក្ស័យធន

Main Office / Mailing Address
1550 Middlesex Street
Lowell, MA 01851

Revere Office
385 Broadway, Suite 305
Revere, MA 02151

978-458-0934 • at@rosataing.com

# កងទ័ពជើងគោករាយការណ៍ថាសកម្មភាពកាប់ឈើក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់នៅតែបន្តកើតមាន

ដកស្រង់ពីCambodia Daily

ផ្សាយថ្ងៃទី០៦ ខែ០១ ឆ្នាំ២០២៥

កងកម្លាំងនៃកងយោធពលខេមរភូមិន្ទ អះអាងថា បទល្មើសព្រៃឈើក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ នៅតែបន្តកើតមាន ក្រោយកម្លាំងចុះប្រតិបត្តិការទប់ស្កាត់ និងបង្ក្រាបបទល្មើស ការកាប់ឈើខុសច្បាប់ក្នុងភូមិសាស្ត្រស្រុកសៀមបូក ខេត្តស្ទឹងត្រែង អស់រយៈពេល ៤ថ្ងៃ។

កងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ (Royal Cambodian Armed Forces) សរសេរលើទំព័រហ្វេសប៊ុករបស់ខ្លួននៅថ្ងៃទី៣ មករា នេះថា បន្ទាប់ពីចុះល្បាតអស់រយៈពេល ៤ថ្ងៃ កម្លាំងបង្ក្រាបបានរកឃើញប្រភេទឈើដូងថែម ត្រូវបានកាត់គល់ផ្តួលរំលំចំនួន ៣៥គល់ និងឈើដែលត្រូវបានអារច្រៀកជាក្តាររួចចំនួន ២៨៥សន្លឹក ដែលស្មើនឹង ០៩ ម៉ែត្រគូប។

ប្រភពដដែលអះអាងថា ក្រៅពីរកឃើញឈើដែលត្រូវបានកាប់ដោយខុសច្បាប់ កម្លាំងល្បាតក៏បានដកហូតគោយន្តកន្ត្រៃសណ្តោងរ៉ឺម៉កចំនួន ៣គ្រឿង និងរណារយន្តចំនួន ១គ្រឿងផងដែរ ដែលត្រូវបានយកមករក្សាទុកក្នុងទីបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តស្ទឹងត្រែង ដើម្បីបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ចចាត់ការបន្តតាមផ្លូវច្បាប់។

កងកម្លាំងប្រតិបត្តិការដដែលនេះ បញ្ជាក់ថា ការចុះល្បាតបទល្មើសព្រៃឈើនេះ គឺអនុវត្តតាមបទបញ្ជាមេបញ្ជាការកងទ័ពជើងគោក លោក ម៉ៅ សុផាន់ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសកាប់ឈើខុសច្បាប់ក្នុងភូមិសាស្ត្រខេត្តស្ទឹងត្រែង ដែលកំពុងកើតមានសព្វថ្ងៃនេះ។

ប្រធានគណៈកម្មការជាតិទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ លោក សៅ សុខា ធ្លាប់បានលើកឡើងកាលពីពេលកន្លងទៅថា បទល្មើសព្រៃឈើដែលតែងតែកើតមាននៅកម្ពុជាទប់ស្កាត់មិនបាន គឺដោយសារតែមន្ត្រីមូលដ្ឋានជាអ្នកបើកដៃឱ្យឈ្មួញពីខាងក្រៅតែប៉ុណ្ណោះ។

លោក សៅ សុខា អះអាងថា មន្ត្រីជំនាញតែងតែផ្តេកផ្តួលចំពោះបញ្ហានេះ ព្រោះថាឈើដឹកតែលើផ្លូវ មិនដែលដឹកខុសពីលើផ្លូវទេ ហើយទីស្នាក់ការបរិស្ថានក៏នៅលើផ្លូវដែរ ដូច្នេះបើមន្ត្រីទាំងនោះមិនផ្សំគំនិតគ្នាទេ បទល្មើសព្រៃឈើក៏មិនកើតឡើងដែរ។ លោកសង្កត់ធ្ងន់ថា បើនៅតែបែបនេះទៀត ប្រទេសកម្ពុជានឹងរលាយហិនហោចជាមិនខាន។

កាលពីអំឡុងឆ្នាំ២០២៤ សារព័ត៌មានអន្តរជាតិ ម៉ុងហ្គាបេ (Mongabay) បានចុះផ្សាយថារយៈពេល ១ឆ្នាំពេញ ប្រទេសកម្ពុជាបានបាត់បង់ព្រៃឈើជាង ១សែនហិកតា (១២១000ហិកតា) ដោយសារតែអំពើពុករលួយ ក្នុងនោះដែនជម្រកសត្វព្រៃព្រៃឡង់ រងការកាប់បំផ្លាញជាប់លំដាប់ថ្នាក់លេខ១។

ប្រភពដដែលរៀបរាប់ថា ការបាត់បង់ព្រៃឈើទាំងនេះ គឺជាប់ពាក់ព័ន្ធនឹងមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលកម្ពុជា រួមទាំងឧកញ៉ាគ្រាក់ៗមួយចំនួនដែលជាសែស្រឡាយរបស់លោក ហ៊ុន សែន ផងដែរ ដូចជា ឧកញ៉ា លី យ៉ុងផាត់ ឧកញ៉ា ទ្រី ភាព និងឧកញ៉ា មិក សុផាន់ណារ៉េត ជាដើម ខណៈក្រុមហ៊ុន Angkor Plywood និងក្រុមហ៊ុន Think Biotech ក៏ជាប់ពាក់ព័ន្ធនឹងការកាប់បំផ្លាញញព្រៃឈើខុសច្បាប់ធ្ងន់ធ្ងរនៅកម្ពុជាដែរ។

ទាក់ទិននឹងបញ្ហានេះ កាលពីដើមខែវិច្ឆិកា ឆ្នាំ២០២៤ នាយករដ្ឋមន្ត្រីកម្ពុជា លោកហ៊ុនម៉ាណែតត្រូវបានព្រះមហាក្សត្រខ្មែរត្រាស់បង្គាប់តែងតាំងជាប្រធានគណៈកម្មាធិការជាតិដឹកនាំអនុវត្តកម្មវិធីផ្តល់ដី ការពារព្រៃ ដើម្បីអភិវឌ្ឍដោយចីរភាព ប៉ុន្តែគេបានរកឃើញថា លោក ហ៊ុន ម៉ាណែត ជាឧក្រិដ្ឋជនព្រៃឈើកំពូលម្នាក់បន្ទាប់ពីលោក ហ៊ុន សែន ដែលជាអ្នកគ្រប់គ្រងផុតលេខក្នុងរចនាសម្ព័ន្ធនៃឧក្រិដ្ឋជនព្រៃឈើនៅប្រទេសកម្ពុជាសព្វថ្ងៃនេះ៕



កងទ័ពជើងគោកចុះឆ្មក់ចាប់ឈើ ក្នុងដែនជម្រកសត្វព្រៃឡង់

# Soldiers Reports That Logging Activities in Prey Lang Wildlife Sanctuary Continue

**Quote from Cambodia Daily**
**Posted on January 06, 2025**

Soldiers of the Royal Cambodian Armed Forces (RCAF) claim that forest crime in the Prey Lang Wildlife Sanctuary continues after a four-day operation to prevent and crack down on illegal logging in Siem Bok district, Stung Treng province.

The Royal Cambodian Armed Forces (RCAF) wrote on its Facebook page on January 3 that after a four-day patrol, the force found 35 trees with fallen trunks. Stems and wood that have been cut into 285 pieces, equal to 9 cubic meters.

The same source claimed that in addition to finding illegally cut wood, the patrol force also confiscated three trucks with trailers and a chainsaw, and were kept at the Stung Treng Provincial Military Operations Area Headquarters to be sent to the competent authorities for legal action.

The same task force confirms that the forest crime patrol is in accordance with the order of the Army Commander, Mr. Mao Sophan, to prevent and crack down on illegal logging in Stung Treng province that is happening today.

Chairman of the National Commission for the Prevention and Suppression of Natural Resource Crimes, Mr. Sao Sokha had previously said that the forest crime that often occurs in Cambodia cannot be prevented because local officials are open to traders from outside.

Mr. Sao Sokha claims that professional officials are always take no action for this ecause timber is only transported on the road, never off the road, and the environmental office is on the road. Therefore, if those officials do not conspire, forest crime will not happen. He stressed that if this continues, Cambodia will be destroyed.

During 2024, the international newspaper Mongabay reported that in one year, Cambodia lost more than 121,000 hectares of forest due to corruption, including the Prey Lang Wildlife Sanctuary crime is prime.

The same source described that the loss of these forests was related to senior officials of the Cambodian government, including some tycoons who are also descendants of Hun Sen, such as Tycoon Ly Yong Phat, Tycoon Try Pheap and Tycoon Mik Sophannareth, while Angkor Plywood and Think Biotech are also involved in serious illegal logging in Cambodia.

In this regard, in early November 2024, the Prime Minister of Cambodia, Mr. Hun Manet, was appointed by the King of Cambodia as the Chairman of the National Committee for the Implementation of the Land Grant, Protect the forest for sustainable Development Program, but it has been found that Mr. Hun Manet is one of the top forest criminals after Mr. Hun Sen, the top manager in the structure of forest criminals in Cambodia today.

# ឯកសារជាភាសាបារាំងសរសេរថា បក្សកុម្មុយនីស្ត យៀកណាមរៀបចំរណសិរ្ស ២ធ្នូ ទាំងអស់

ដកស្រង់ពីCambodia Daily

ផ្សាយថ្ងៃទី០៦ ខែ០១ ឆ្នាំ២០២៥

តំណាងរាស្ត្របក្សប្រឆាំង លោក អ៊ុំសំអាន លើកឡើងថា រណសិរ្ស២ធ្នូ ឆ្នាំ១៩៧៨ ត្រូវបានក្រុងហាណូយ បង្កើតឡើងដើម្បីហែហាមកងទ័ពវៀតណាម ក្នុងនាមបងប្អូនរួមអាវុធ ដែលរៀបគម្រោងឈ្លានពានទឹកដីខ្មែរ ក្រោមលេសផ្តួលរំលំរបបខ្មែរក្រហមប៉ុណ្ណោះ ដោយសន្យាផ្តល់អំណាចគ្រប់គ្រងទឹកដីខ្មែរទៅឱ្យអ្នកចូលរួមបង្កើតរណសិរ្សនេះ។

លោក អ៊ុំ សំអាន សរសេរលើទំព័រហ្វេសប៊ុករបស់ខ្លួនដោយដកស្រង់ខ្លឹមសារក្នុងសៀវភៅជាភាសាបារាំង Anatomie d'un Cauchemar នៅថ្ងៃទី៣ មករា នេះថា រណសិរ្ស ២ធ្នូ ឆ្នាំ១៩៧៨ ត្រូវបានបង្កើតឡើងដោយកងទ័ពវៀតណាម មិនមែនបង្កើតឡើងដោយខ្មែរស្នេហាជាតិនោះទេ។

ប្រភពដដែលលើកឡើងថា ក្រោយពីលោក #ហ៊ុនសែន លោក #ហេងសំរិន លោក #ជាស៊ីម និងលោក #ហេងសំកៃ រត់គេចខ្លួនពីយោធាខ្មែរក្រហមតាមសម្លាប់ ចូលទៅទឹកដីវៀតណាម ពួកគេត្រូវបានកងទ័ពវៀតណាម ចាប់ឃុំខ្លួនអស់រយៈពេលជាង ២០ថ្ងៃ។

លោកថា ក្រោយមកក៏ត្រូវមេបញ្ជាការកងទ័ពវៀតណាម លោក ឡេ ឌឹកថ ដោះលែងឱ្យមានសេរីភាពវិញ ក្រោមកិច្ចសន្យាបម្រើផែនការវៀតណាម ជាថ្នូរនឹងការជួយជ្រោមជ្រែងពួកគេឱ្យដឹកនាំប្រទេសកម្ពុជាទៅថ្ងៃមុខ។

តំណាងរាស្ត្របក្សប្រឆាំងរូបនេះ បញ្ជាក់ថា ការដោះលែងលោក ហ៊ុន សែន លោក ហេង សំរិន លោក ជា ស៊ីម និងលោក ហេង សំកៃ ដោយសារមេបញ្ជាការកងទ័ពវៀតណាម លោក ឡេ ឌឹកថ មានផែនការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ នៅសាលាហ្វឹកហ្វឺន ធូឌឹក ដែលជាអតីតជំរំប៉ូលិសបង្កើតដោយកងកម្លាំងអាមេរិកាំងស្ថិតនៅជាយក្រុងព្រៃនគរនោះ។

លោក អ៊ុំ សំអាន គូសបញ្ជាក់ថា អតីតក្រុមកម្មាភិបាលខ្មែរក្រហមដែលនៅក្រោមបង្គាប់លោក សោ ភឹម ដូចជា លោក ហ៊ុន សែន លោក ហេង សំរិន លោក ជា ស៊ីម និងលោក ហេង សំកៃ ជាដើម ដែលនាំគ្នារត់ទៅប្រទេសវៀតណាម ព្រោះតែភ័យខ្លួនពីការតាមសម្លាប់របស់ទាហាន ប៉ុល ពត ប៉ុណ្ណោះ មិនមែនរត់ទៅរំដោះជាតិដូចរឿងព្រេងនិទានរបស់លោក ហ៊ុន សែន ដែលនិពន្ធកុហកពលរដ្ឋខ្មែរក្នុងខ្សែភាពយន្ត «កូនប្រុសក្រោមពន្លឺព្រះចន្ទពេញបូណ៌មី» ដែលគាត់បានតាក់តែងឡើងនោះទេ។

ការអះអាងនេះ ធ្វើឡើងស្របពេលដែលរឿងកូនប្រុសក្រោមពន្លឺព្រះចន្ទពេញបូណ៌មី បានរំលេចនូវថ្ងៃ ២ ធ្នូ ឆ្នាំ១៩៧៨ ដែលជាថ្ងៃបង្កើតរណសិរ្សសាមគ្គីរំដោះជាតិចេញពីរបបប្រល័យពូជសាសន៍ ត្រូវលោក ហ៊ុន សែន ផ្សព្វផ្សាយជាបន្តបន្ទាប់នៅពេលនេះ។

រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលត្រូវបានបង្កើតដោយលោក ហេង សំរិន លោក ជា ស៊ីម និងលោក ហ៊ុន សែន កាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ ក្រោមការជ្រោមជ្រែងយ៉ាងពេញទំហឹងរបស់កងទ័ពវៀតណាម បានប្តូរឈ្មោះទៅជា ក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គី

**តទៅទំព័រទី២២**




Comme pour contrebalancer la nouvelle prudence du régime, sa propagande se fit de plus en plus outrancière. « La puanteur des Vietnamiens monte jusqu'au ciel », affirmait *Tung Padevat* à ses lecteurs. Ils sont tombés tellement bas qu'on les méprise comme des moins que rien, car [ils] ne pensent qu'à tendre leur sébile... implorant la charité de tout le monde. » C'était un piètre argument face à un ennemi qui, au même moment, préparait méthodiquement la chute des Khmers rouges.

Pendant que Pol discutait avec Deng Xiaoping à Pékin, Le Duc Tho rencontrait Heng Samrin, Pen Sovann et les autres exilés khmers à Thu Duc, un ancien camp de police américain dans les faubourgs de Hô Chi Minh-Ville. Il leur déclara que le Vietnam avait l'intention de lancer une invasion générale du Cambodge au début de la saison sèche et que le mouvement de résistance khmère récemment constitué combattrait aux côtés de ses « frères d'armes » vietnamiens. En attendant, les exilés devaient créer un mouvement de coalition, le Front d'union nationale pour le salut du Kampuchéa (FUNSK), susceptible de prendre le pouvoir après la chute du régime de Pol Pot. L'histoire se répétait. Pour la troisième fois en trois décennies, les autorités de Hanoi organisaient un mouvement de résistance

Foreign Relations, 1977–78

... Later on the Vietnamese put me into jail for twenty-two days. The Vietnamese refused to believe what I told them — that the Khmer Rouge were going to attack." ...

រូបភាពឯកសារជាភាសាបារាំងបក្សកុម្មុយនីស្តយៀកណាម

# Documents in French says that the Communist Party of Vietnam organized the 2 December Front

Quote from Cambodia Daily
Posted on January 06, 2025

The Opposition party lawmaker Oum Sam An said that the December 2, 1978 Front was formed by Hanoi to accompany the Vietnamese army on behalf of the armed forces who planned to invade Cambodian territory under the pretext of overthrowing the Khmer Rouge regime, promising to give power to control the territory of Cambodia to the participants in the formation of this front.

Oum Sam An wrote on his Facebook page, quoting in the French book Anatomie d'un Cauchemar on January 3, that the December 2, 1978 Front was formed by the Vietnamese army, not by the patriotic Khmer.

The same source said that after #Hun Sen, #Heng Samrin, #Chea Sim and Heng Samkai escaped from the Khmer Rouge army killing them, they entered into Vietnamese territory, they were detained by the Vietnamese army for a year. 20 days.

He said that later on they were released by the commander of the Vietnamese army, Le Duc Tha, under a contract to serve the Vietnamese plan in exchange for helping them to lead Cambodia in the future.

The opposition lawmaker confirmed that the release of Hun Sen, Heng Samrin, Chea Sim and Heng Samkay was due to the commander of the Vietnamese army, Le Duc Tho has plans to form the United Front for National Salvation on December 2, 1978, at the Tuduc Training School, a former police camp set up by US forces on the outskirts of Prey Nokor.

Mr. Oum Sam An pointed out that former Khmer Rouge cadres under Mr. So Phim, such as Mr. Hun Sen, Mr. Heng Samrin, Mr. Chea Sim and Mr. Heng Samkay, fled to Vietnam because of fear of being chased by Pol Pot soldiers, he did not run for national liberation like the legend of Hun Sen, who wrote a lie to the Cambodian people in the film "Son under the full moon" which he composed.

This claim comes at a time when the story of the son under the full moon highlights on December 2, 1978, the day the United Front for National Liberation from the genocidal regime was published by Hun Sen.

Cambodian National Salvation United Front, founded by Heng Samrin, Chea Sim and Hun Sen on December 2, 1978 under the full support of the Vietnamese army, it was renamed the National Council of the United Front for the Development of Motherland Cambodia, which is still used today.

On this issue, Mr. Hun Sen once claimed that the Vietnamese Volunteer Army had strongly supported the Kampuchean United Front for National Salvation on December 2, 1978 to overthrow the genocidal regime of Pol Pot until victory on January 7, 1979.

In addition, the Vietnamese Embassy in Cambodia also claimed that the support of the Vietnamese army to the United Front for National Salvation on December 2, 1978 until the victory on January 7, 1979 was because the Communist Party of Vietnam, together with the Vietnamese army and people, exercised their legal right to rescue the Cambodian people from the Khmer Rouge genocidal regime at that time.

Be reminded that The Cambodia

**Please see /22**

# ពលរដ្ឋខ្មែរស្នើរាជរដ្ឋាភិបាលចាត់ការម៉ឺងម៉ាត់លើមន្ត្រីកម្លាំងប្រដាប់អាវុធពាក់ព័ន្ធគ្រឿងញៀន

ដកស្រង់ពីCambodia Daily
ផ្សាយថ្ងៃទី០៣ ខែ០១ ឆ្នាំ២០២៥

រាជរដ្ឋាភិបាលអនុវត្តវិធានការច្បាប់ឱ្យបានម៉ឺងម៉ាត់ជាទីបំផុតចំពោះកងកម្លាំងដែលជាប់ពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន ដើម្បីឱ្យអ្នកពាក់ព័ន្ធផ្សេងទៀតលះបង់អំពើល្មើសនេះដោយខ្លួនឯង។

អ្នកប្រឹក្សាយោបល់ផ្នែកអភិវឌ្ឍន៍ផ្នត់គំនិត និងការស្រាវជ្រាវ លោក សេក សុជាតិ ប្រាប់សារព័ត៌មាន The Cambodia Daily នៅថ្ងៃទី២ មករា នេះថា ការរកឃើញនូវការប្រើប្រាស់ និងការជួញដូរគ្រឿងញៀនក្នុងចំណោមមន្ត្រីកម្លាំងប្រដាប់អាវុធជាតិ គឺជាភស្តុតាងជាក់ស្តែងមួយដែលបង្ហាញថា បទល្មើសនេះច្បាស់ជាមានការសហការគ្នាជាប្រព័ន្ធ ទើបការប្រើប្រាស់ និងការជួញដូរនេះមានសកម្មភាពរហូតមក។

លោក សេក សុជាតិ លើកឡើងថា ប្រសិនបើរដ្ឋាភិបាលមិនអាចជីកកកាយយកមន្ត្រីអនុវត្តច្បាប់ដែលពាក់ព័ន្ធនឹងគ្រឿងញៀនមកផ្តន្ទាទោសឱ្យអស់ទេ គឺនៅតែជាបញ្ហាប្រឈមសម្រាប់សង្គមជាតិដដែល ពីព្រោះវិធានការរដ្ឋាភិបាលក្នុងការថែរក្សា#សន្តិសុខសង្គមនឹងត្រូវជាប់គាំង ដោយសារតែមន្ត្រីខិលខូចទាំងអស់នេះ។

អ្នកឃ្លាំមើលរូបនេះបញ្ជាក់ថា រដ្ឋាភិបាលមិនត្រូវបណ្តែតបណ្តោយឱ្យមានគ្រឿងញៀនជ្រៀតចូលក្នុងប្រព័ន្ធដឹកនាំរបស់ខ្លួនរហូតធ្វើឱ្យមន្ត្រីកងកម្លាំងក្នុងក្របខ័ណ្ឌរដ្ឋក្លាយជាភ្នាក់ងារចែកចាយវត្ថុខុសច្បាប់ទាំងនេះជាដាច់ខាត។

លោក សេក សុជាតិ គូសបញ្ជាក់ថា អ្នករងគ្រោះពីទង្វើល្មើសនេះ គឺជារដ្ឋាភិបាលខ្លួនឯងទៅវិញតែប៉ុណ្ណោះ ព្រោះថាពលរដ្ឋនឹងរិះគន់ទៅលើរដ្ឋាភិបាលចំពោះបញ្ហានេះ ដោយសារតែមិនអាចអនុវត្តនូវគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពតាមការសន្យារបស់ខ្លួន។

កាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ មេបញ្ជាការកងរាជអាវុធហត្ថផ្ទៃប្រទេស លោក សៅ សុខា បានបញ្ជាឱ្យចាប់ខ្លួនមេបញ្ជាការរងកងរាជអាវុធហត្ថខេត្តតាកែវលោកង៉ែតចាន់ឌីនិងនាយសេនាធិការមូលដ្ឋានកងរាជអាវុធហត្ថស្រុកត្រាំកក់ លោក លុយ សារុំ រួមទាំងលោក ស៊ិន សុវណ្ណារិទ្ធ ដែលជាជំនួយការការិយាល័យគ្រឿងញៀនខេត្តផងដែរ ពីបទពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន។

ជុំវិញបញ្ហានេះ អ្នកនាំពាក្យកងរាជអាវុធហត្ថផ្ទៃប្រទេស លោក អេង ហ៊ី ឱ្យដឹងថា កម្លាំងជំនាញពិតជាបាននាំខ្លួននាយអាវុធហត្ថទាំង ៣នាក់ទៅសួរនាំនៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តកណ្តាល ពាក់ព័ន្ធករណីគ្រឿងញៀនពិតប្រាកដមែន។

ទាក់ទិននឹងបញ្ហានេះរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស សុខា ធ្លាប់បានត្អូញត្អែរកាលពីពេលកន្លងទៅថា បញ្ហាគ្រឿងញៀនបានក្លាយជាហានិភ័យដ៏ធំសម្រាប់ប្រទេសកម្ពុជាសព្វថ្ងៃនេះ ព្រោះសមត្ថកិច្ចបង្ក្រាបបានគ្រឿងញៀនមិនត្រឹមតែរយគីឡូក្រាមទេ គឺចូលដល់តោនឯណោះ។

រឿងដោយឡែកមួយទាក់ទងនឹងបញ្ហាសុខុមាលភាពនៃសង្គមជាតិខ្មែរដែរនោះ គឺរឿងអនាម័យ។ តាមទីភ្នាក់ងារព័ត៌មានបក្សកុម្មុយនីស្តចិន ស៊ីនហួ នៅថ្ងៃព្រហស្បតិ៍ ទី២ ខែមករា នេះ រាជរដ្ឋាភិបាលប្តេជ្ញាថានឹងបំបាត់សំរាមស្បោងប្លាស្ទិកឲ្យអស់ពីផ្លូវសាធារណៈក្នុងឆ្នាំថ្មីនេះ។

ដំណាលពេលគ្នានេះមន្ត្រីនៃក្រសួង

តទៅទំព័រទី១៨



ចាប់វ៉ៃខ្មោះកងកម្លាំងប៉េអឹមខេត្តតាកែវ ៣ នាក់ ពាក់ព័ន្ធគ្រឿងញៀន

# The Royal Government implements the strictest legal measures against the forces involved in the drug problem so that other relevant people can abandon the crime by themselves

**Quote from Cambodia Daily**
**Posted on 03 January 2025**

Mindset Development and Research Consultant, Sek Socheat told The Cambodia Daily on January 2 that the discovery of drug use and trafficking among National Armed Forces officials is clear evidence that the crime was systematically co-operative, and its use and trafficking have always been active.

Mr. Sek Socheat said that if the government cannot dig up and prosecute all drug-related law enforcement officials, it will still be a challenge for the society because the government's measures to maintain social security will be stalled due to all these corrupt officials.

The watchdog emphasizes that the government must not allow drugs to infiltrate its system until it becomes a state-owned force that distributes these illegal items.

Mr. Sek Socheat emphasized that the victims of this crime are the government itself, because the people will criticize the government for not being able to implement the village-commune safety policy as promised.

On January 1, 2025, the Commander of the National Gendarmerie, Mr. Sao Sokha, ordered the arrest of the Deputy Commander of the Takeo Provincial Gendarmerie, Mr. Nget Chandy, and the Chief of Staff of the Tram Kak District Gendarmerie Mr. Luy Sarom, including Mr. Sin Sovannarith, an assistant to the provincial drug office, were charged with drug-related offenses.

Regarding this issue, the spokesman of the National Gendarmerie, Mr. Eng Hy, said that the specialized force actually brought the three Gendarmerie officers to the Kandal Provincial Gendarmerie Command for interrogation related to the real drug case.

In this regard, the Minister of Interior, Mr. Sar Sokha, had previously complained that the drug problem has become a major risk for Cambodia today, because the authorities have cracked down, not only a hundred kilograms of drugs, but also tons.

A separate issue related to the welfare of Cambodian society is hygiene. According to the Chinese Communist Party (Xinhua) news agency, on Thursday, January 2, the government vowed to remove plastic bags from public roads in the new year. At the same time, officials from the Ministry of Rural Development claim that out of 17 million people by 2024, 92% of the general population is hygienic and hope that by 2030 it will be 100% hygienic. 21% have clean / pure water to drink.

Foreign investors observed and published in the Cambodia Investment Review that in the new year 2025, Cambodia has a deadline in Prakas No. 204 of the Ministry of Labor on August 29, 2024, which is a national holiday from 21 days to 23 days per year: 15 days on weekdays and 5 days on holidays of Saturday or Sunday.

## Lowell Primary Care Center

**មណ្ឌលថែទាំសុខភាព Lowell**

1075 Westford Street, Unit 204
Lowell, MA 01851 • (978) 455-7992

## Lynn Primary Care Center

**មណ្ឌលថែទាំសុខភាព Lynn**

280 Union Street, Unit 402
Lynn, MA 01901 • (781) 780-7755



**Chhan Touch, FNP-BC**
ឆាន់ ទូច



**Practice Manager**
**Channa Khan, CMA**
អ្នកគ្រប់គ្រងគ្រូពេទ្យ
ចាន់ណា ខាន់



**Sophor Chhour, LMHC**
សុព័រ ឈួ



**Nalyne Dom, FNP-BC**
ណាលីន ដំ



**Nida Lam, FNP-BC**
នីដា ឡាម



**Maredy Sar, DNP, NP-C**
ម៉ារីឌី ស



**Miadette Pheng-Phal, DNP, NP-C**
មីយ៉ាដេត ផេងផល

## Now Accepting New Patients

ឥឡូវនេះ បើកទទួលអ្នកជំងឺថ្មី

***Family Medicine***
*ថែទាំសមាជិកគ្រួសារ*

***Behavioral Health***
*ថែទាំសុខភាពផ្លូវចិត្ត*

**We Accept MassHealth, Medicare and Other Health Insurances**
**Our Staff Speaks Khmer**

យើងទទួល **MassHealth Medicare** និងការធានារ៉ាប់រងសុខភាពផ្សេងៗ
បុគ្គលិករបស់យើងនិយាយភាសាខ្មែរ

តមកពីទំព័រទី ១៣

## អ្នកជំនួញចិនប្ដឹងឧកញ៉ា ហ៊ុន តូ

ជូនថ្នាក់ដឹកនាំ។ ប៉ុន្តែបន្ទាប់ពីទទួលបានលុយគ្រប់ចំនួន លោក ហ៊ុន តូ មិនត្រឹមតែមិនបានបំពេញការងារតាមការសន្យាទេ ថែមទាំងបានបញ្ជូនក្រុមជនអន្ធពាលមកចាប់ជំរិតថែមទៀត តែរូបគេបានគេចខ្លួនចេញពីប្រទេសកម្ពុជាដើម្បីសុវត្ថិភាពបានទាន់ពេល។

ជនជាតិចិនឈ្មោះ SUN RUIFENG រូបនោះបញ្ជាក់ថា ក្នុងនាមខ្លួនជាអ្នកវិនិយោគបរទេសមានចិត្តស្រឡាញ់ និងមើលឃើញឱកាសវិនិយោគក្នុងប្រទេសកម្ពុជា និងមានបំណងចង់ចូលរួមអភិវឌ្ឍតាមរយៈការវិនិយោគនេះ ប៉ុន្តែគួរឱ្យសោកស្ដាយដោយរូបលោកត្រូវបានលោក ហ៊ុន តូ បោកប្រាស់ទៅវិញ។

អ្នកជំនួញជនជាតិចិនរូបនេះបញ្ជាក់ថា រូបគេបានចំណាយប្រាក់ជាច្រើនលើលោក ហ៊ុន តូ ដូចជាការចាយវាយផ្សេងៗ ការជូនកាដូជានាឡិកាដៃម៉ាកថ្លៃៗ និងស្រាថ្លៃៗ ជាដើម។

កាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០២៥ អតីតអ្នកឧកញ៉ា ហេង សិទ្ធី អគ្គនាយកក្រុមហ៊ុន Maritime Group ក៏បានប្ដឹងលោក ហ៊ុន តូ ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លោក កើត រិទ្ធ ពីបទប្រឌិតមួលបង្កាច់ បន្ទាប់ពីពាក្យបណ្ដឹងមួយត្រូវបានផ្សព្វផ្សាយឡើងវិញកាលពីពេលថ្មីៗនេះ។

លោក ហេង សិទ្ធី បញ្ជាក់ថា លោកបានចូលខ្លួនបំភ្លឺ និងដោះស្រាយសំណុំរឿងដែលលោក ហ៊ុន តូ បានប្ដឹងរូបលោករួចរាល់អស់ហើយកាលពីឆ្នាំ ២០២៣ កន្លងទៅ ហើយការយកសំណុំរឿងនេះមកផ្សព្វផ្សាយឡើងវិញតាមរយៈលោក ផេង វណ្ណៈ គឺជាការគប់គិតគ្នារវាងលោក ហ៊ុន តូ និងចៅក្រមស៊ើបសួរលោក ពេជ្រ វិជ្ជាធរ រួមទាំងលោក ផេង វណ្ណៈ ក្នុងបំណងប្រឌិតរឿងមិនពិត លាបពណ៌ និងមួលបង្កាច់លើរូបលោកប៉ុណ្ណោះ។

ទាក់ទិននឹងបញ្ហានេះ លោក ហេង សិទ្ធី ក៏បានបង្ហោះពាក្យបណ្ដឹងដែលលោក ហ៊ុន តូ បានប្ដឹងរូបលោកពាក់ព័ន្ធនឹងការផលិត ជួញដូរនូវសារធាតុញៀន និងការសម្អាតប្រាក់កាលពីចុងខែមិថុនា ឆ្នាំ២០២៣ ផងដែរ។

អតីតអ្នកឧកញ៉ា ហេង សិទ្ធី អះអាងថា ការដែលលោក ហ៊ុន តូ ប្ដឹងលោកនៅពេលនោះ គឺជាល្បិចដើម្បីទប់ស្កាត់កុំឱ្យលោកប្ដឹងលោក ហ៊ុន តូ ដែលបានរំលោភយកដីធ្លីរបស់លោកប៉ុណ្ណោះ



លោក ហ៊ុន តូ

បន្ទាប់ពីអ្នកឧកញ៉ាត្រកូលហ៊ុនរូបនេះបានបោកប្រាស់យកដីរបស់លោក និងដៃគូសហការរបស់លោកក្នុងទំហំទឹកប្រាក់ប្រមាណជា ២៥០លានដុល្លារអាមេរិក កាលពីពេលកន្លងទៅនោះ ក្នុងនោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់លោកក៏មានទំហំជាទឹកប្រាក់ប្រមាណជា ៩០លានដុល្លារអាមេរិកដែរ ដែលរូបលោកបានត្រឹមបៀមទុក្ខក្នុងចិត្តរហូតដល់ពេលនេះតែប៉ុណ្ណោះ។

យ៉ាងណាក៏ដោយ ជុំវិញបណ្ដឹងរបស់អតីតអ្នកឧកញ៉ា ហេង សិទ្ធី លើលោក ហ៊ុន តូ នៅពេលនេះ ត្រូវអ្នកនាំពាក្យក្រសួងយុត្តិធម៌ ច្រានចោលទាំងស្រុង ក្រោមហេតុផលថា អ្វីៗដែលអតីតអ្នកឧកញ៉ា ហេង សិទ្ធី បានផ្សព្វផ្សាយលើបណ្ដាញសង្គម គ្រាន់តែជាព័ត៌មានសម្រាប់ក្រសួងពិនិត្យ និងវិភាគប៉ុណ្ណោះ ពុំមែនជាបណ្ដឹងផ្លូវការដែលត្រូវតែចាត់ការទៅតាមនីតិវិធីនោះទេ៕

## A Beijing businessman has sued Hun Sen's nephew, Tycoon Hun To, to Justice Minister Keut Rith for breach of trust in a $ 9 million fraud and attempted kidnapping.

From Page 13

On January 3, 2025, former tycoon Heng Sethy, CEO of Maritime Group, also sued Hun To to the Minister of Justice, Mr. Keut Rith, for fabricating slander after a lawsuit was recently re-broadcast.

Mr. Heng Sethy stated that he had already clarified and resolved the case that Mr. Hun To had already sued him in 2023, and that case would be republished through Mr. Pheng Vannak. It is a conspiracy between Mr. Hun To and the investigating judge, Mr. Pich Vicheathor, including Mr. Pheng Vannak, in order to fabricate false stories, paint/smear and slander him.

In this regard, Mr. Heng Sethy also posted a complaint that Mr. Hun To sued him in connection with the production and trafficking of drugs and money laundering in late June 2023.

Former tycoon Heng Sethy claims that Hun To sued him at the time was a ploy to prevent him from suing Hun To for encroaching on his land after the tycoon swindled his land and his partners in the amount of about 250 million US dollars in the past, including his personal wealth of about 90 million US dollars, which he only suffered until now.

However, a lawsuit filed by a spokesman for the Ministry of Justice has now been dismissed by former Ministry of Justice spokesman Heng Sithy on the grounds that everything that former tycoon Heng Sethy posted on social media was just information for the Ministry to inspect and Analyse, not a formal complaint that must be processed.

តមកពីទំព័រទី ១៦

## ពលរដ្ឋខ្មែរស្នើរាជរដ្ឋាភិបាលចាត់...

អភិវឌ្ឍន៍ជនបទ អះអាងថា ក្នុងចំណោមពលរដ្ឋ ១៧លាននាក់ក្នុងឆ្នាំ២០២៤ ប្រជាពលរដ្ឋទូទៅ ៩២% មានអនាម័យ ហើយសង្ឃឹមថាឆ្នាំ២០៣០ នឹងមានអនាម័យ ១០០%។ ២១% មានទឹកស្អាត/បរិសុទ្ធទទួលទាន។

ក្រុមអ្នកវិនិយោគបរទេសសង្កេតឃើញ ហើយផ្សាយក្នុងទស្សនាវដ្ដីវិនិយោគទុនកម្ពុជា (Cambodia Investment Review) ថា ក្នុងឆ្នាំថ្មី ២០២៥ ប្រទេសកម្ពុជាមានថ្ងៃកំណត់ក្នុងប្រកាសលេខ២០៤ នៃក្រសួងការងារ នៅថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០២៤ ជាទិវាបុណ្យជាតិ កើនពី ២១ថ្ងៃដល់ ២៣ថ្ងៃក្នុងមួយឆ្នាំ៖ ១៥ថ្ងៃចំថ្ងៃធ្វើការក្នុងសប្ដាហ៍ និង ៥ថ្ងៃទៀតចំថ្ងៃឈប់សម្រាកថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ៕



ថ្នាំញៀន

# ក្រុមតស៊ូមតិវាយតម្លៃការដឹកនាំរបស់នាយករដ្ឋមន្ត្រីជាង១ឆ្នាំនេះ ថាកាន់តែធ្វើឱ្យកម្ពុជារអិលទៅរកជ្រោះនយោបាយនិងសេដ្ឋកិច្ច

ដកស្រង់ពីCambodia Daily
ផ្សាយថ្ងៃទី០៣ ខែ០១ ឆ្នាំ២០២៥

ក្រុមអ្នកតស៊ូមតិកម្ពុជា (Cambodian Advocacy Team, CAT) លើកឡើងថា តំណែងនាយករដ្ឋមន្ត្រីរយៈពេល ១៦ខែរបស់លោក ហ៊ុនម៉ាណែត កាន់តែរុញឱ្យប្រទេសកម្ពុជារអិលទៅរកជ្រោះនយោបាយ និងសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរ ព្រោះលោក ហ៊ុន ម៉ាណែត នៅតែបន្តបោះបង់ផលប្រយោជន៍ជាតិដើម្បីតែការពារអំណាច និងផលប្រយោជន៍គ្រួសារ និងបក្ខពួក។

ក្រុមអ្នកតស៊ូមតិកម្ពុជា Cambodian Advocacy Team ចេញលិខិតវាយតម្លៃលើការដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០២៥ នេះថា ការដឹកនាំរបស់លោក ហ៊ុន ម៉ាណែតនៅតែស្ថិតក្នុងទម្រង់ដឹកនាំបែបលោក #ហ៊ុនសែន ជាឪពុកដដែល។ ឧទាហរណ៍ជាក់ស្តែង #អំពើពុករលួយ ការ#រំលោភច្បាប់ រំលោភ#រដ្ឋធម្មនុញ្ញ រំលោភ#សិទ្ធិមនុស្ស ចាប់អ្នកមានគំនិតផ្ទុយដាក់គុក គឺនៅតែបន្តកើតមានក្នុងការដឹកនាំរបស់គាត់អស់រយៈពេលជាង ១ឆ្នាំមកនេះ។

ក្រៅពីនេះទៀត ក្រសួង-ស្ថាប័ននីមួយៗនៅតែបន្តតែងតាំងបក្ខពួកខ្លួនឯងជាជំនួយការ ទីប្រឹក្សា រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ជាដើម រាប់រយនាក់ដូចមុន ដែលទង្វើនេះបង្ហាញអំពីការខ្វះខ្វាយថវិកាជាតិយ៉ាងធ្ងន់ធ្ងរ ដំណាលពេលដែលប្រទេសកម្ពុជាកំពុងក្លាយជាកូនបំណុលបរទេសជិតវិណ្ឌកទៅហើយនោះ។ ប្រភពដដែលលើកឡើងថា រដ្ឋាភិបាលរបស់លោក ហ៊ុន ម៉ាណែត និងលោក ហ៊ុន សែន បានសម្រេចបោះចោលសុចរិតភាព និងយុត្តិធម៌ ដោយការចាប់យកការដឹកនាំជាលក្ខណៈគ្រួសារ និងបក្ខពួកនិយមតាមរយៈការរក្សា និងបង្កើនផលប្រយោជន៍គណបក្សប្រជាជនកម្ពុជា ក្រោមទ្រឹស្តីរក្សាចាស់បង្កើតថ្មី ដើម្បីបុព្វហេតុអ្នកបន្តវេន ដោយទុកផលប្រយោជន៍ជាតិទាបជាងផលប្រយោជន៍ផ្ទាល់ខ្លួន និងបក្ខពួកបន្តទៅទៀត។



លោកនាយករដ្ឋមន្ត្រីថ្មី ហ៊ុន ម៉ាណែត

តាមអត្ថន័យនៃវិទ្យាសាស្ត្រនយោបាយ របៀបដឹកនាំបែបនេះស្ថិតក្នុងរង្វង់ខ្លឹមសារពាក្យអង់គ្លេសយ៉ាងត្រឹមត្រូវថា oligarchy គឺការគ្រប់គ្រងក្តោបក្តាប់វាសនាប្រទេសជាតិដោយមនុស្សមានអំណាចមួយក្រុមតូច nepotism គឺគ្រួសារនិយម Cronyism គឺបក្ខពួកនិយម និង patronage គឺតែងតាំងមុខតំណែងធំៗតាមបែបគ្រួសារបក្ខពួកនិយមបែងចែកប្រយោជន៍បុណ្យស័ក្តិ និងលាភសក្ការៈជុំវិញគ្នីគ្នារបស់គេ។

នាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត បានបន្តតំណែងនាយករដ្ឋមន្ត្រីពីលោក ហ៊ុន សែន ជាឪពុកអស់រយៈពេល ១ឆ្នាំ ៦ខែហើយ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ កន្លងទៅនេះ។ អ្នកវិភាគបស្ចិមប្រទេសនិយាយថា គេមិនទាន់ឃើញសញ្ញាណាមួយគួរផ្តល់ក្តីសង្ឃឹមថា លោក ហ៊ុន ម៉ាណែត ដែលរៀននៅប្រទេសលោកសេរីប្រជាធិបតេយ្យ បង្ហាញការគ្រប់គ្រងប្រទេសខុសពីដានចាស់នៅឡើយទេ។

ជុំវិញបញ្ហានេះ អតីតមេដឹកនាំបក្សប្រឆាំង លោក សម រង្ស៊ី បានលើកឡើងកាលពីពេលថ្មីៗនេះថា ក្រុមគ្រួសារលោក ហ៊ុន សែន នឹងជាប់ឈ្មោះជាវង្សត្រកូលបំផ្លាញជាតិក្នុងប្រវត្តិសាស្ត្រខ្មែរតជំនាន់ ព្រោះវង្សត្រកូលមួយនេះបានគប់គិតជាមួយបរទេសបំផ្លាញទឹកដី និងភោគទ្រព្យរបស់ខ្មែរឱ្យវិនាសសាបសូន្យក្នុងរបបដឹកនាំរបស់គាត់។

លោក សម រង្ស៊ី លើកឡើងថា ពលរដ្ឋខ្មែរបាត់បង់ទឹកដី បាត់បង់ឯករាជភាពជាតិ បាត់បង់សេរីភាព បាត់បង់លទ្ធិប្រជាធិបតេយ្យ បាត់បង់ព្រៃឈើ និងធនធានធម្មជាតិ បាត់បង់អត្តសញ្ញាណជាតិ បាត់បង់ប្រព័ន្ធអនុគ្រោះពន្ធពីសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក ជាដើម ដោយសារតែការដឹកនាំបន្តពូជរបស់លោក ហ៊ុន សែន តែមួយគត់។

វត្ថុអរូបដ៏ប្រសើរឧត្តមពីរយ៉ាង ដែលចាត់ទុកជាកេតនភណ្ឌសម្រាប់ជាតិសាសន៍មួយ គឺឯករាជ្យជាតិពេញបរិបូណ៌ និងសេរីភាពពេញលេញ៕

---

តមកពីទំព័រទី ១២

## ដំណើរ"ចៅដក"យកឈ្នះលើ២៤ម៉ោង

អធ្រាតយប់ទី២១នេះ រហូតដល់អាធ្រាតនៃយប់ស្អែកទី២២ តើនឹងប្រើពេលតែ២៤ម៉ោងមែនឬទេ? ហួសហេតុទេដឹង? បងប្អូន២នាក់ គឺសុជា នឹង សុភា មានភារកិច្ច បើករថយន្តជូន«ចៅដក»សំដៅទៅកាន់ស្ថានីយរថយន្តឈ្នួល«ផ្លីកប៊ូស Flixbus»ទៅកណ្តាលក្រុងរ៉ែន ក្រោមសម្លេងជូនពរ ឲ្យធ្វើដំណើរប្រកបដោយជោគជ័យ ពីបងប្អូនខ្មែរនៅទីស្នាក់ការសមាគមខ្មែរ។ ចៅដក នឹងចេញដំណើរតែម្នាក់ឯង នៅជំណាក់ការទី១ដំបូងគេ ចម្ងាយជិត៤០០គីឡូម៉ែត្រ ពីរ៉ែនទៅទីក្រុងប៉ារីស។ សុជា នឹង សុភា បានទម្លាក់ចៅដក នៅស្ថានីយរថភ្លើងក្រុងស្ថានីយរថភ្លើងខាងជើង នៅម៉ោង១០.៣០ ដែលឋិតនៅក្បែររបងរថយន្តប៊ូសជាប់គ្នា ក្នុងដំណើរចៅដកតាម«ជំនិះរថយន្តប៊ូសរាត្រី»នាម៉ោង១.៤០នាទិ ទៅកាន់រដ្ឋធានីក្រុងប៉ារីស ។

ចៅដកមានឥវ៉ាន់ខ្លះនាំទៅជាមួយ ដូចជាសាក់ស្តាយនៅខ្នងមួយនឹងវ៉ាលីសទម្ងន់២០គីឡូមួយ ហើយគិតថា«ខ្លួននឹងទៅសម្រាក់បន្តិច នៅអាគារស្ថានីយរថភ្លើង នៅរង់ចាំពេលវេលាចេញដំណើរ ពីព្រោះខាងក្រៅនៃចំណតប៊ូសវាត្រជាក់ខ្លាំងណាស់ នាយប់ខែកត្តិកនោះ»។ ដើម្បីសម្រាកកាយ ចៅដក បានទៅរកបន្ទប់ទឹកជាមុន ដែលមានតែមួយ នៅស្ថានីយសម្រាប់អ្នកដំណើររាប់ម៉ឺននាក់ជារៀងរាល់ថ្ងៃ តែបន្ទប់ទឹកនោះបានបិទទ្វារនៅម៉ោង៩យប់ទៅហើយ បើទោះជាមានអ្នកដំណើរបន្តរចេញចូលរហូតដល់ម៉ោង១១ក៏ដោយ នេះជាសោកនាថកម្មទី១ ដែលចៅដកគិតថា«ទីនេះជាគម្រោងគ្រប់គ្រងសេដ្ឋកិច្ចនៃមនុស្សគ្មានបេះដូង» តាយាយមួយគូរក៏យល់ដូចចៅដក បានណែនាំឲ្យចៅដក ទៅបន្ទោបង់នៅសួនច្បារខាងក្រៅ គួរឲ្យអាម៉ាសមែន! ។

ប៉ុន្តែគ្រោះកាចទី២ក៏បានមកកក់ដរ ចៅដកភ្លាមទៀតដែរ អាចនឹងរំខានគំរោងដ៏ផុយស្រួយឲ្យបោះបង់ចោលបាន ដោយនៅពេលម៉ោង១១យប់ ក៏ស្រាប់តែមាននាយសន្តិសុខស្ថានីយបានមកដេញអ្នកអង្គុយរង់ចាំចេញដំណើរទាំងអស់រួមទាំងជនគ្មានជម្រកមួយចំនួនឲ្យចាកចេញពីព្រោះគេត្រូវបិទស្ថានីយនៅម៉ោង១២រហូតដល់ភ្លឺ ចៅដកសួរថា«តើឲ្យអ្នកដំណើរទៅរង់ចាំនៅឯណា?» គេពុំមានចម្លើយទេ ពីព្រោះខាងរថយន្តប៊ូស ជាឯកភាពផ្សេងពីរថភ្លើង... ចៅដកសួរទៀតថា នៅខាងក្រៅត្រជាក់ខ្លាំងណាស់ ហើយក៏ពុំមានឃើញជម្រកណាមួយ ដែលអាចការពារអ្នកដំណើរបានទេ.. គេក៏តបមកវិញថា នោះជាបញ្ហារបស់ក្រុមហ៊ុនប៊ូសដែលត្រូវដោះស្រាយឲ្យភ្ញៀវរបស់ពួកគេ... ចៅដកក៏បង្ហាញភាពតក់ស្លុត ដែលត្រូវរង់ចាំ

តទៅទំព័រទី២៣

# ក្រុមតន្ត្រីអរុណរះនៅឡូវ៉ែល

ឡូ ថ្ងៃទី១៩មករា២០២៥

សុទ្ធតែអតីតក្រុមតន្ត្រីករជើងចាស់ប្រមាណជា១០នាក់ បានស្ម័គ្រចិត្តមកហាត់ភ្លេងកំសាន្តឡើងវិញ នៅមន្ទីរធ្វើ«តាក់»របស់លោក រីទ្ធី សៅ នៅរៀងរាល់ថ្ងៃអាទិត្យ តាំងពី៣ខែមកហើយ បន្ទាប់ពីពួកគាត់បានខកខានឈប់លេងភ្លេង ជាច្រើនឆ្នាំ ដោយអាយុច្រើននឹងនឿយណាយពីកាងារដដែលៗ គួរឲ្យធុញថប់។ លោក សំបូរ អ្នកចូលនិវត្តន៍ម្នាក់ បានប្តើមយក«គីតា»សូឡូ មកលេងកំសាន្តជាមួយលោកវីរៈ ដែលលេង«គីតា»មួយទៀត នឹងលោក ម៉ម តារា ហៅប្រុញក៏យក«គីតា»បាស់សំឡេងធំរបស់គាត់មកលេងដែរ ជួយវាយស្គរកំដរដោយលោក រីទ្ធី នៅពេលទំនេរពីកាងារបន្តិច នៅមានលោក យឿន ក៏មកជួយវាយស្គរដៃយ៉ាងរីករាយ ពេលគាត់បានចប់ពីកាងារភោជនីយដ្ឋាន។ ពួកគាត់ប្តើមរបៀបនេះក៏ចេះតែមានបន្តរយ៉ាងព្យាយាមនឹងអុករអឺន រហូតដល់សម្រេចចិត្តមូលមាត់គ្នា បង្កើតបានជាក្រុមភ្លេងមួយ ដើម្បីអរគុណនឹងកំដរសហគមន៍ដែលពួកគាត់ធ្លាប់រស់នៅ ក៏កើតជាក្រុមគ្រួសារខ្មែរ ដែលនៅពេលនោះមិនទាន់មានឈ្មោះនៅឡើយទេ ។

លោក សុខផល ប៉ែន ដែលតែងតែមកច្រៀងកំសាន្ត ពេលចេញពីធ្វើការពេលព្រលប់ ជាមួយក្រុមអ្នកលេងភ្លេង ជាមួយនឹងស្ត្រីមេផ្ទះឬអ្នកចេញពីធ្វើការ ដូចជានាងម៉ៅឬ នាង ស៊ូស៊ី...ជាដើមក៏បានក្លាយជាអ្នកសម្របសម្រួលការលំបាកស្រណុក ដ៏មាន«វ័យក្មេង»របស់ក្រុមភ្លេងដ៏ថ្មីថ្មោងនោះទៅ។ នៅដើមខែធ្នូ២០២៤ ក្រុមតន្ត្រី«យុវចាស់»នោះក៏បានធ្វើការសម្រេចចិត្តតម្លើងទៅដំណាក់ការមួយទៀត គឺចេញសម្តែងជាក្រុមនៅថ្ងៃទី១៨ខែធ្នូ២០២៤ នៅចន្លោះការសម្តែងរបស់ក្រុមតន្ត្រីដ៏ពេញនិយមមួយទៀត គឺក្រុមតន្ត្រីក្មេងខិល«Badboy»តែធ្វើមិនបានសម្រេច ក៏បែកគំនិតចង់ចេញសម្តែងដោយខ្លួនឯងតែម្តង តែចុងក្រោយនេះមានឈ្មោះមួយហើយ គឺក្រុម«តន្ត្រីអារុណរះ»ដែលត្រូវបញ្ចេញរស្មី នៅថ្ងៃទី១៨ មករា ២០២៥ នៅភោជនីយដ្ឋាន«សំពៅមាស»នាទីក្រុងឡូវែល។ ពេលវេលាសម្តែងកាន់តែកៀក អ្នកថ្មីក៏មកដល់មានលោក សម្បត្តិ កាន់«អ៊ិក» លោក សំអាន កាន់«កុងគ្គា» សូលីនាកាន់សូឡូ..តែត្រូវបង្ខំហាត់សមច្រើនដងជញ្ជូនគ្រឿងភ្លេងទៅហាត់ ឥតនឿយហាត់ហាត់បញ្ចប់នៅរសៀលថ្ងៃ១៨នោះ



ក្រុមតន្ត្រីករជើងចាស់(អារុណរះ)ចេញមកបង្ហាញជាលើកទី១នៅសំពៅមាស ឡូវែល

តែម្តង ស្លៀកពាក់ស្មើរមិនទាន់ តែប្រែរូបទៅជាសភាពបុរសនារី«សង្ហារ»បានទាន់ពេល។

ថ្ងៃសម្ភោធក្រុមភ្លេង«តន្ត្រីអារុណរះ»មកដល់ ភ្ញៀវស្រីប្រុសក្នុងសម្លៀកបំពាក់ក្រុង ស្រស់ស្អាតគ្រប់ៗគ្នា ប្រមាណ២០០នាក់រួមទាំងភ្ញៀវកិត្តិយស ជាមន្ត្រីសាលាក្រុង ជាសមាជិកសភារដ្ឋនឹងជាក្រុមប្រឹក្សាសាលារៀន..បានមកអបអរសាទរ លើកទឹកចិត្តតន្ត្រីនៃមន្ត្រីចូលនិវត្តន៍ខ្មែរឡូវែលដោយទឹកមុខរីករាយ នាំគ្នាមករាំកម្សាន្តជាមួយនឹងបទអនុស្សាវរីយកម្ពុជាសម័យ១៩៦០ ៧០ ៨០..ជាមួយអ្នកចម្រៀងឯកប្រចាំក្រុម គឺនាង ពៅ សំណាង នឹងលោក ប្រាក់ អារុណ នឹងដារាចម្រៀងកិត្តិយសនាង សូ សុភ័ក្រ្ត ក៏មកចូលរួមកំដរបរិយាកាស ដែលពោរពេញទៅដោយជំនាញនៃអាជីពយ៉ាងពេញចិត្ត ចំពោះគុណភាពសម្តែង... ទាំងអស់គ្នា បានទទួលនូវភាពរីករាយពេញមួយរាត្រី នឹងអំណរអរគុណដល់«ក្រុមចាស់ទុំ» ដែលបែរជាអ្នកចេញមកកំដរ«ក្រុមយុវវ័យ»នៅឡូវែលនេះទៅវិញ៕



សុផល ប៉ែន ស្វាគមន៍ភ្ញៀវ



លោក សម្បត្តិ និងលោក សំបូរ រីករាយនឹងបានចេញមុខបំរើអារម្មណ៍សារជាថ្មី



រាត្រីរាំកំសាន្តយ៉ាងរីករាយជាមួយនឹងក្រុមអារុណរះ

# DCR Ramps Up Recruitment for Lifeguards and Seasonal Staff for Summer 2025

**Candidates can earn up to $27 plus up to $1,250 in bonuses; additional roles for park rangers, interpreters and more**

BOSTON – The Massachusetts Department of Conservation and Recreation (DCR) today announced open applications for lifeguards, head lifeguards, pool and waterfront supervisors, and water safety instructors for the 2025 summer season. These positions will serve at the agency's 32 guarded beaches, 24 swimming pools, and two wading pools throughout the state. DCR offers competitive hourly wages ranging from $22 to $27, depending on the position and required certifications. In addition, qualified candidates who apply early and work through the end of the season can earn up to $1,250 in bonuses.

"Our beaches welcome thousands of visitors each year, and lifeguards are key to ensuring a safe and fun experience," said Governor Maura Healey. "As a DCR lifeguard, you'll be at the heart of a high-energy, rewarding role that helps people enjoy their time while keeping them safe at our pools and waterfronts."

"I loved my time working as a lifeguard growing up – it's a fun and important job. You'll spend your summer outside, make good money and maybe even save lives," said Lieutenant Governor Kim Driscoll. "Lifeguards are leaders in their communities – they are first responders who are trained to calmly and efficiently manage crisis situations at our waterfronts and pools. I encourage anyone who is interested to apply."

DCR is offering an early sign-on bonus of $500 for candidates who submit




a complete hiring packet by Wednesday, May 1, 2025. Lifeguards who stay through Sunday, August 17, 2025 – the end of the pool season – will receive a $250 retention bonus. Additionally, those who work through Labor Day, Monday September 1, 2025, marking the end of the beach season, will receive an extra $500 bonus.

To apply for a lifeguard position, candidates must be at least 16 years old by their date of hire, complete lifeguard training, and be certified in first aid and CPR. DCR offers free lifeguard training classes through May for candidates who commit to working before the summer season begins. As first responders, lifeguards play a crucial role in ensuring the safety of visitors at state-managed beaches and pools.

DCR will open its 81 designated swimming areas across Massachusetts Memorial Day Weekend (May 24-26, 2025), and the season will run through Labor Day (September 1, 2025). All DCR pools open in June and are equipped with accessible chair lifts and/or ramps to allow visitors of all abilities to enter the water. DCR also provides beach mats and floating beach wheelchairs at many of its beaches.

"Climate changes is making our summers hotter than ever. That's why safe access to our state pools and beaches is so important for families and residents. It is especially vital for our environmental justice communities," said Energy and Environmental Affairs Secretary Rebecca Tepper. "Lifeguards help our communities cool down on hot summer days. It's all about keeping these communities safe while seeking relief from the heat."

"Every summer, thousands of families, residents, and visitors of all ages, abilities and backgrounds visit our beautiful beaches and pools," said DCR Commissioner Arrigo. "Recruiting and hiring trained and qualified lifeguards is crucial to ensuring that our beaches and pools are safe and welcoming places for everyone. If you are a strong swimmer who is looking for a summer job, reach out to us and apply today."

Most of DCR's pool and waterfront positions are seasonal, with a 40-hour work week, including weekends and holidays. Limited part-time lifeguard and instructor positions (up to 20 hours per week) may also be available. To learn more about available pool and waterfront positions or to apply for open positions, visit mass.gov/lifeguards.

As part of the effort to recruit lifeguards and other pool and beach safety staff for the upcoming summer season, DCR is collaborating with partner state agencies, state and local elected officials, municipalities, and educational institutions to spread the word about this opportunity for good-paying summer employment. DCR's lifeguard recruitment is a year-round effort. In the fall, DCR ran multilingual radio PSAs recruiting candidates to enroll in the agency's free lifeguard training classes on JAMN945 and La Mega. Staff have also been promoting the job opportunities at job fairs and expos.

DCR is also hiring for other seasonal positions for Memorial Day through Labor Day, including rangers, park interpreters, supervisors, forestry assistants, building and ground maintenance workers, and office assistance. Some positions will run from April through October. For more information, interested applicants should visit www.mass.gov/guides/dcr-seasonaljobs

---

តមកពីទំព័រទី ០៤

## ព្រឹត្តិការគួរឲ្យចង់ដឹងក្នុងពិភពលោក

មេរីកនោះរួចហើយ» គឺនឹងធ្វើដោយសន្តិភាព នឹងដោយសារប្រទេសជាប់គ្នាទាំង២នេះមានផលប្រយោជន៍រួមគ្នាជាច្រើន ដូចជាការងារ នឹងផលិតផលឧបភោគបរិភោគជាដើម។ ក៏ប៉ុន្តែ ក៏មានអ្នកឈរឈ្មោះបន្តរវេន6រូប រួចហើយដែរ ដែលមានលោកស្រី ហ្វ្រីឡិន នឹងលោក ខានី.ជាមនុស្សសេដ្ឋកិច្ច នឹងធានាគារ ដែលបានផ្តើមធ្វើការឃោសនា សម្រាប់ថ្ងៃបោះឆ្នោតនៅខែមិនា២០២៥ខាងមុខ ទៅហើយ។

### ៤ប្រទេសស៊ីរី: ក្រុមអតីតឧទ្ទាម ត្រៀមគ្រប់គ្រងស៊ីរី

កាលពីលេខមុន យើងបានរាយការថាអតីតប្រធានាធិបតីតពូជជាង៥០ឆ្នាំ បាស្ហា អាល់អាសាដ បានរត់ចោលស្រុក ទៅជ្រកកោននៅប្រទេសរុស្សី គឺវាយចាញ់ក្រុមឧទ្ទាម ដោយពេលនោះ សមមិត្ររុស្សី រវល់នឹងសង្គ្រាមដែលខ្លួនបង្កើតនៅអ៊ុយក្រែន ក៏រត់ចោលខ្លួន, សមមិត្រអ៊ីរ៉ង់ ក៏រវល់នឹងអ៊ីស្រាអែលវាយចូលប្រទេសខ្លួន ក៏ដកខ្លួនថយ, ក្រុមអេសបូឡាភេរវករ រងដំបងអ៊ីស្រាអែល នៅជួយស៊ីរីមិនបាន ក៏រត់ចេញទៅដែរ, ដូច្នេះ អាល់អាសាដ នៅតែម្នាក់ឯងមិនអាចទប់នឹងក្រុមឧទ្ទាមរួចទេ ក៏ដាក់មេប្រូចដែរ។

ឥឡូវតើស៊ីរីនឹងទៅជាយ៉ាងណាជាមួយនឹងអ្នកឈ្នះថ្មី?មានមេដឹកនាំថ្មីម្នាក់នៃក្រុមឧទ្ទាម អាម៉េដ អាលសារា ដែលគេធ្លាប់ស្គាលថា អាប៊ូមហាមេដ អាល ជូឡានី ជាមនុស្សលេចមុខជាងគេ ក្នុងក្រុម ហាយ៉ាត់តាអៀ អាលស្ហាម Hayat Tahrir Al-Sham (HTS), ។ មហាមេដ អាល់សារា ជាមេក្រុមអ៊ីស្លាមមួយក្នុងចំណោមក្រុមជាច្រើន ដែលនឹង



លោកនាយករដ្ឋមន្ត្រីកាណាដា យូស្ទីន ទ្រូដូ

រៀបបង្កើតចំក្រុមប្រឹក្សាដឹកនាំប្រទេសស៊ីរី ដោយត្រូវធ្វើឲ្យហើយនូវរដ្ឋធម្មនុញ្ញ ដែល«រក្សាប្រទេសនេះឲ្យបានរស់នៅយូរអង្វែងមិនមែនសម្រាប់តែដឹកនាំប្រទេសតែថ្ងៃនេះទេ» នេះជាសេចក្តីថ្លែងការរបស់អាល់សារា ទៅកាន់អ្នកកាសែត។

សហរដ្ឋអាមេរិក បានសម្តែងសេចក្តីសង្ឃឹមចំពោះអនាគតនៃប្រទេសស៊ីរី នៅក្នុងសន្តិភាពថ្មីថ្មោងរបស់ខ្លួន ដោយការរៀបចំឲ្យមានការបោះឆ្នោតដ៏ត្រឹមត្រូវមួយ ដោយចង់រក្សាចំណងជាមួយបច្ចឹមប្រទេស នឹងបណ្តេញប្រទេសរុស្សីចេញពីប្រទេសស៊ីរីផង។ លោក អាលសារា ត្រៀមប្រើពេលដើម្បីរៀបចំក្រុមប្រឹក្សាដឹកនាំប្រទេស នឹងឲ្យទៅដល់ការបោះឆ្នោតសាលកនៅ៣ឆ្នាំខាងមុខ។ សហភាពអឺរ៉ុប មានបារាំង អាល្លឺម៉ង់ជាដើម បានចូលទៅមានទំនាក់ទំនងជាមួយថ្នាក់ដឹកនាំថ្មីឡើងវិញហើយ។

ប្រទេសស៊ីរី បានខកខានធ្វើការបោះឆ្នោតនៅឆ្នាំ២០២១ នៅឆ្នាំ២០២២ក៏មានការធ្វើប្រជាមតិមួយ ដើម្បីបន្តលោក អាបា អាល់អាសាដ ជាប្រធានាធិបតីតាំងពីពេលនោះមក៕

តមកពីទំព័រទី ១៥

## ឯកសារជាភាសាបារាំងសរសេរថា...

អភិវឌ្ឍន៍មាតុភូមិកម្ពុជាវិញ ដែលបានប្រើជាផ្លូវការរហូតដល់សព្វថ្ងៃនេះ។

ជុំវិញបញ្ហានេះ លោក ហ៊ុន សែន ធ្លាប់បានអះអាងថា កងទ័ពស្ម័គ្រចិត្តវៀតណាម បានជួយជ្រោមជ្រែងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ២ ធ្នូ ១៩៧៨ យ៉ាងខ្លាំងក្លា ដើម្បីផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត រហូតទទួលបានជ័យជម្នះនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

ជាងនេះទៀត ស្ថានទូតវៀតណាមប្រចាំនៅកម្ពុជា ក៏ធ្លាប់បានអះអាងដែរថា ការជួយជ្រោមជ្រែងពីសំណាក់កងទ័ពវៀតណាម ដល់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា កាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ រហូតទទួលបានជ័យជម្នះនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គឺដោយសារបក្សកុម្មុយនីស្តវៀតណាម ជាមួយកងទ័ព និងប្រជាជនវៀតណាម បានអនុវត្តសិទ្ធិស្របច្បាប់ជួយសង្គ្រោះប្រជាជនកម្ពុជាពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមនៅពេលនោះ។

សូមរំឭកជាថ្មីថា៖ សារព័ត៌មាន The Cambodia Daily ធ្លាប់បានផ្សាយរឿងហ្នឹងច្រើនដងដែរហើយ ដោយសំអាងលើឯកសារ និងសាក្សីរស់ជាអតីតកម្មាភិបាលខ្មែរក្រហមផង ជាអតីតប្រជាពលរដ្ឋរស់នៅតំបន់ផ្លែសន្ទូច ស្រុកស្នួល ខេត្តក្រចេះ ដែលជាតំបន់មូលដ្ឋានបង្កើតរណសិរ្ស២ធ្នូ នោះ។ សាក្សីរស់នៅប្រទេសអូស្ត្រាលី ដែលជួបប្រទះនឹងព្រឹត្តិការណ៍គ្រានោះផ្ទាល់ ធ្លាប់បានរៀបរាប់ប្រាប់យើងថា កម្មាភិបាលយោធាយៀកណាម បានកេណ្ឌប្រជាជនក្នុងតំបន់នោះស្លៀកខ្មៅៗ ទៅឈរ ឬអង្គុយពីមុខ ហើយរៀបជនជាតិយៀកណាមស្លៀកពណ៌ដូចគ្នានៅពីក្រោយ ហើយថតរូបដើម្បីបង្ហាញអន្តរជាតិថា ពួកកម្មាភិបាលយោធាខ្មែរក្រហមបែកបាក់គ្នាប្រុងបះបោររំលំរដ្ឋអំណាច ប៉ុល ពត នៅភ្នំពេញ។ នាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង អមដំណើរដោយ ឡេ ឌឹកថ ធ្វើដំណើរទៅក្រុងមូស្គូ សហភាពសូវៀត ទំនងជាទៅបង្ហាញរូបថតប្រាប់ចៅហ្វាយថា របបខ្មែរក្រហមនឹងត្រូវរលំហើយ ហើយយោងតាមកាតព្វកិច្ចយុទ្ធមិត្តសង្គមនិយមអន្តរជាតិ ហាណូយ ត្រូវតែជួយ។

ក្នុងសៀវភៅ ហេតុអ្វីយៀកណាមឈ្លានពានប្រទេសកម្ពុជា និពន្ធដោយបណ្ឌិត Stephen P. Morris លេខាបក្សឡេ យ័ន ធ្លាប់បង្ហើបអំពីការរៀបផែនការផ្តួល ប៉ុល ពត តាំងពីឆ្នាំ១៩៧៦ ពីព្រោះប៉ុល ពត និយាយដដែលៗតែអំពីរឿងកំណត់ព្រំដែនជាមួយយៀកណាម។ ក្នុងឆ្នាំ១៩៧៧ ប៉ុល ពត ក៏ចាប់បំបាត់ពួកកម្មាភិបាលយៀកមិញ ឬហាណូយនិយម ដែលគេហៅថា ពួកក្បាលយួនខ្លួនខ្មែរ ដោយប្រើ តា ម៉ុក ដែលដឹងថាពួកនោះនៅម្តុំណា។ ខ្មែរយៀកមិញប្រមាណ ៥ពាន់នាក់ទៅតាមមេយៀកមិញនាឆ្នាំ១៩៥៤ ជាង ២ពាន់នាក់វិលពីហាណូយវិញនៅឆ្នាំ១៩៧១ មករួមដៃជាមួយទ័ពព្រៃយៀកណាមខាងជើង-យៀកកុង និងខ្មែរក្រហមតាមការអំពាវនាវពីសម្តេច នរោត្តម សីហនុ។

សៀវភៅនោះបានស្រង់សម្តី ឡេ យ័ន ដែលនិយាយថា៖ យៀកណាមស្គាល់ខ្មែរ ដឹងត្រូវប្រើវិធីក្តៅនៅពេលណា វិធីត្រជាក់នៅពេលណា។ គេរើសយកថ្ងៃល្អ ដែលពិភពលោកសេរីប្រារព្ធថ្ងៃបុណ្យកំណើតព្រះយេស៊ូគ្រិស្ត ២៥ ធ្នូ បើកប្រតិបត្តិការវាយប្រហារលុកលុយឈ្លានពានប្រទេសកម្ពុជាតែម្តង៕

## Documents in French says that the Communist Party of Vietnam organized the 2 December Front

From Page 15

Daily has published this story many times, citing documents and witnesses, former Khmer Rouge cadres, former residents of Phleus Santouch, Snuol district, Kratie province, which is the base area for forming the front. 2 December witnesses in Australia who witnessed the incident once told us that Vietnamese military cadres mobilized local people in black to stand or sit in front and arrange for Vietnamese to wear the same color in the background and take photos to show the international community that the Khmer Rouge military cadres are divided and ready to overthrow the Pol Pot regime in Phnom Penh. Prime Minister Pham Van Dong, accompanied by Le Duc Tha, traveled to Moscow, the Soviet Union was likely to show a photo to tell the boss that the Khmer Rouge regime would be overthrown and that according to the international socialist comrades Hanoi must help.

In the book Why Vietnam Invaded Cambodia, written by Dr. Stephen P. Morris, Secretary of the Le Yuan Party, the plot to defeat Pol Pot dates back to 1976, because Pol Pot repeatedly talked about demarcating the border with Vietnam. In 1977, Pol Pot also eliminated the Viet Minh or Hanoiist cadres, known as the Khmer-Vietnamese, using Ta Mok, who knew where they were. About 5,000 Khmer Viet Minh followed Viet Minh in 1954, more than 2,000 returned from Hanoi in 1971 to join the North Vietnamese guerrillas - Viet Cong and the Khmer Rouge at the urging of Samdech Norodom Sihanouk.

The book quotes Le Yuan as saying "Vietnam knows the Khmer know when to use the hot method and the cold method." They chose a good day for the free world to celebrate the birth of Jesus Christ on December 25, launching an operation to invade Cambodia.

# Massachusetts Ranks #1 in National Education Assessment

From Page 03

The administration has also been focused on reducing chronic absenteeism and supporting students getting back into the classroom where they can learn and access supports like universal school meals and mental health services. This year, the administration launched the 'Your Presence is Powerful' campaign to emphasize the importance of attending school and delivered golden basketballs donated by the Celtics and signed by the 2024 World Champion team to the Massachusetts schools that had the greatest drop in chronic absenteeism. The statewide chronic absenteeism rate has decreased 2.5 percentage points from 22.2 percent at the end of the of the 2022-23 school year to 19.7 percent at the end of the 2023-24 school year. That is also an 8 percentage point decrease from the end of the 2021-22 school year.

"Two years ago, this administration hit the ground running to stabilize and heal our education system as we recover from the pandemic. We have been focused on accelerating student learning, including through high-dosage math tutoring and investing in early literacy," said Education Secretary Patrick A. Tutwiler. "We also know that there remain achievement gaps that must be addressed across the board, and we are going to keep working to see to it that we are #1 for all students in our state."

"These results, combined with our MCAS results, show us that we have strong schools but that much remains to be done, both to recover from the pandemic and to address student achievement," said Russell D. Johnston, acting commissioner of elementary and secondary education. "I'm grateful to all the educators, families and students who have improved attendance and strengthened student supports. This shared focus on a strong foundation will help make early literacy initiatives and other efforts more successful."



Photo via NAEP

តមកពីទំព័រទី ១៩

# ដំណើរ"ចៅដក"យកឈ្នះលើ២៤ម៉ោង

អស់រយៈពេល៣ម៉ោង នៅខាងក្រៅរបង គ្មានជម្រក គឺសញ្ញានៃភាពជំយោយៅជាទីបំផុត ជាលើកទី២។

រំលងម៉ោង១២អាធ្រាតថ្ងៃទី២២ធ្នូ នៅពេលដើរចេញមកដល់ខាងក្រៅ ចៅដកបានឃើញជនគ្មានជម្រក២.៣នាក់ ដែលនៅខាងក្រៅរួចជាស្រេច ដែលពួកគេត្រូវប្រឈមនឹងធាតុអាកាសត្រជាក់ស្រឹបនាខាងក្រៅបរិវេណនោះពេញ១យប់ តើអ្នកទាំងនោះអាចនៅរស់រហូតដល់ភ្លឺបានឬទេ? ចៅដកមិនបានហៅរកជំនួយពីក្រុមមិត្រ ដែលទំនងជានៅរាំច្រៀងយ៉ាំងរីករាយ នៅឯសមាគម នៅឡើយទេ ឬក៏ហៅទៅកូនចៅឲ្យជួយក៏ទេដែរ...ដោយចង់ពិសោធន៍ជាមួយនឹងអ្នកឯទៀត ថាតើ បើប្រមាណ៣ម៉ោង បិតនៅក្នុងពិភពដ៏ត្រជាក់ក្បែ រសូន្យអង្សា តើខ្លួនឯងនឹងទៅជាយ៉ាងណា?

គាប់ជួននៅតាមផ្លូវរង់ចាំ មានស្ត្រីគ្មានជំរកម្នាក់រុំខ្លួនជិត និយាយថា«នាងមិនទាន់បានហូបអាហារនៅឡើយទេ» ធ្វើឲ្យចៅ ស្រយ៉ុតក្នុងចិត្ត តែមិនអាចធ្វើអ្វីបានទេ ក៏គិតក្នុងចិត្តថា មានគេយ៉ាប់ជាងអាត្មាអញទៅទៀត!... នៅមានយុវជនម្នាក់ទៀត ដែលបានខកជើងដំណើរ ត្រូវតែរង់ចាំបន្តរដំណើររហូតដល់ថ្ងៃស្អែក យើងបានជជែកគ្នារំងាប់ពេលរង់ចាំ នឹងរំងាប់ធាតុអាកាសត្រជាក់ បានខ្លះ យុវជននោះ ក៏រងកម្មខ្លាំងណាស់ដែរ! តែដោយខ្យល់ត្រជាក់បានបក់មកកាន់តែខ្លាំង ជម្រុញឲ្យចៅដក ណែនាំឲ្យយុវជននោះ ទៅរកកន្លែងដែលអាចកាពារខ្យល់នឹងឲ្យអាចសម្រាកបានខ្លះ, រីឯចៅដកវិញអូសវ៉ាលីសតែម្នាក់ឯង ដើរទៅដើរមកឃឹតៗដូចជាហាត់ប្រាណផង គ្រាន់បានជាកំដៅខ្លួនខ្លះដែរ... បន្តិចមក ភ្ញៀវអ្នកដំណើរខ្លះៗបានមកដល់បន្តរបន្ទាប់ រហូតដល់ម៉ោង១.៣០ព្រឹក ភ្លៀងក៏ធ្លាក់ឈុលមកដំបូលដ៏តូចនៃស្ថានីយ មិនអាចទប់ទឹកភ្លៀងមិនឲ្យសាចទទឹកបានខ្លះទេ... បន្តិចមកទៀត ក៏ឡានឈ្នួលដឹកប៊ូសក៏មកដល់តែម្តង ភាពធូរស្រាលក្នុងចិត្តក៏កើតឡើងវិញបន្តិច ហើយចៅដក ក៏ប្តើមផ្តោតអារម្មណ៍ទៅគោលដៅបន្ទាប់ គឺបន្តរដំណើរពីចំណាតទីក្រុងរ៉ែន ទៅកាន់ចំណាត ប៉ៃស៊ី នាទិក្រុងប៉ារីស(ដែលមានចម្ងាយ៤០០គ.ម.) ក្នុងរថយន្តឈ្នួលហ្លឹកប៊ូស ចៅដកឆ្លៀតសំងំដេកបាន៣៤ម៉ោងមុននឹងទៅដល់ប៉ារីស... ដែលនៅប៉ារីសនោះ ចៅដកត្រូវបន្តរដំណើរទៅកាន់វាលយន្តហោះ«សាលឌឺគ្គោល»ទៀត ដើម្បីធ្វើដំណើរចេញតាមជើងយន្តហោះ Jetblue 1408 ដែលបាន



នៅពេល"ចៅដក"ធ្វើដំណើរនៅពេលយប់ ក្រុមមិត្តភក្តិខ្លួននៅរាំកំសាន្តនៅអាគីរនៅឡើយ

គ្រោងទុកនៅម៉ោង៦.៥០នាទីព្រឹក ដដែលនេះ ទៅកាន់ទីក្រុង«ញូយ៉ក»នៃសហរដ្ឋអាមេរិក។

នៅលើរថយន្តឈ្នួល បន្ទាប់ពីធ្វើដំណើរអស់ប្រមាណជិត៥ម៉ោង ក៏មកដល់ចំណាត«រថយន្តប៊ូសប៉ៃស៊ី»ក្រុងប៉ារីស ដែលនៅទីនោះ ចំណាតរថយន្ត បង្ហាញពីរចនាបទនៃចំណាតរថយន្តឆ្នាំ១៩៥០ ដែលប្រណិតភាពមានយ៉ាងខ្សត់ខ្សោយ អ្នកដំណើរមកពីគ្រប់ខេត្តក្រុងនាព្រឹកនោះ ប្រញាប់ប្រញាល់គ្រប់គ្នា ដើម្បីទៅឲ្យដល់ផ្ទះទាន់ថ្ងៃបុណ្យណូអែល។ ចៅដកត្រូវអូសវ៉ាលីសដើរចេញពីចំណាតរថយន្តទៅកាន់មេត្រូ តាមផ្លូវលុំក្នុងចម្ងាយប្រមាណ២០នាទី ទាំងភ្លៀងរលឹមស្រិចៗ កាត់តាមពហុកីឡាដ្ឋានអន្តរជាតិប៉ៃស៊ីដ៏ល្បីល្បាញមួយ គឺដោយសារប៉ារីសទើបនឹងទទួល«កីឡាអូឡាំពិក»កាលពី៥ខែមុន នៅទីនោះ, ល្បីល្បាញមួយជាន់ទៀត ដោយប្រទេសបារាំងពេលនោះ ឆ្លងកាលវិបត្តិនយោបាយធ្ងន់ធ្ងរ ដោយរៀបចំទទួលកីឡាអូឡាំពិកដ៏សម្បើមមួយ តែដោយគ្មានរដ្ឋាភិបាលទេ លោកនាយករដ្ឋមន្ត្រី«អាតាល់»បានធ្លាក់ពីដំណែង គ្មានគណរដ្ឋរដ្ឋមន្ត្រី ជាអ្នកគ្រប់គ្រងអស់២ខែ ហើយមកទល់ថ្ងៃនេះក៏រដ្ឋាភិបាលបន្ទាប់«បាញេ»ឡើងបន្ត ក៏ធ្លាក់១ទៀត រដ្ឋាភិបាលបន្តរចុងបញ្ចប់ គឺលោក«បាយរូ» ក៏មិនទាន់មានគណរដ្ឋមន្ត្រីគ្រប់គ្រាន់នៅឡើយផង... តែស្រុកបារាំងនៅតែមានប្រក្រតីភាព នឹងសុវត្ថិភាព នៅឡើយទេ។

ម៉ោង៦ព្រឹកនៃថ្ងៃ២២ ដំណើរពីម៉េត្រូប៉ៃស៊ីទៅដល់វាលយន្តហោះសាលដឺគ្គោល ចៅដកគិតថា ត្រូវជិះរថភ្លើងក្រោមដី Metro រួចបន្តរដោយជិះ«រថភ្លើងក្រៅក្រុងRER»ទៀតទើបបានទៅដល់ចំណាត់យន្តហោះ«សាលដឺគ្គោល២»... ប៉ុន្តែនៅពេលបន្តដំណើរទៅដល់កន្លែងទិញសំបុត្រម៉េត្រូ មានអ្នកដំណើរប្រមាណ៥០នាក់ រង់ចាំយ៉ាងកកកុញស្រេចទៅហើយ ពីព្រោះចំណាតមេត្រូទើបតែនឹងបើកទ្វារមនុស្សម្នាសម្រុកចូលទៅទិញសំបុត្រនៅម៉ាស៊ីនស្វ័យប្រវត្តដែលមានចំនួន៦គ្រឿង ដែលតែម៉ាស៊ិនពាក់កណ្តាលប៉ុណ្ណោះដំណើរការដូចនេះ ត្រូវចាំរង់ ជិត១ម៉ោង ទើបដល់វេនចៅដក ធ្វើឲ្យឃឹតដំណើរ ស្តាយពេលខ្លាំងណាស់!... អីចឹងហើយក្នុងប្រវែងផ្លូវប្រមាណតែ២០គ.ម.សោះ ចៅដកប្រើពេលជិត៣ម៉ោងទើបបានដល់ព្រលានយន្តហោះ... ស៊យមែន ឲ្យតែយ៉ាងនេះឃឹតពេលអស់ហើយ ! មកដល់ត្រឹមដំណាក់ការដំបូង តាំងពីចេញដំណើរមក ចៅដកប្រើពេលអស់ ជិត១០ម៉ោង រួចបាត់ទៅហើយ...។

- តើចៅដកចង់ធ្វើអ្វី ? គឺចង់បង្ហាញថា ពេលវេលាក្នុងមួយថ្ងៃ មិនមែនមានតែ២៤ម៉ោងទេ !
- ដូច្នេះកំពុងតែបង្ហាញអ្វី ? ពន្លូតពេលដែលឃឹតដូចកៅស៊ូ ដោយប្រើល្បឿនដែលលឿនជាងម៉ោង នឹងចម្ងាយឆ្ងាយ
- តើឧប្បស័គ្គទាំងឡាយ អាចបញ្ឈប់ដំណើរពិតប្រាកដ ជាក់ស្តែងរបស់«ចៅដក»ចង់ឈ្នះពេល២៤ម៉ោងបានឬទេ ?
- សូមរង់ចាំអានភាគបន្តនៅលេខបន្ទាប់ លើទំព័រដដែលនេះ៕




សូម
ដាក់ពាក្យ
ថ្ងៃនេះ !
សាលារៀនសាធារណៈសហគមន៍
ឆាទ័រនៃទីក្រុងឡូវែល
សាលារៀនឆាទ័រ (LCCPS) គឺជាសាលារៀនសាធារណៈ(រដ្ឋ)ឆាទ័របំរើសេវាកម្មអប់រំដល់សិស្សានុសិស្សចំនួន៨១៥នាក់
ចាប់ពីថ្នាក់មត្តេយ្យបឋមដល់ថ្នាក់ទី៨ ដោយឥតបង់ថ្លៃការសិក្សា ស្ថិតនៅទីប្រជុំជនក្រុងឡូវែលនៃរដ្ឋម៉ាស្សាឈូសិត ។
ថ្ងៃផុតកំណត់ទទួលពាក្យ
ថ្ងៃទី២៨ ខែកុម្ភៈ ២០២៥
វគ្គផ្សព្វផ្សាយព័ត៌មាន
• ថ្ងៃទី៦ ខែកុម្ភៈ ២០២៥
ថ្ងៃចាប់ឆ្នោត
ថ្ងៃទី៥មីនា២០២៥@៥:៣០ល្ងាច
សូមទំនាក់ទំនងតាមលេខ
(978) 323 - 0800
សាលារៀនឆាទ័រគឺសំរាប់កូនលោកអ្នក ?
• គាំទ្រភាសាអង់គ្លេសELL & តម្រូវការពិសេស
• កម្មវិធីថ្ងៃសិក្សារយៈពេលវែង
• កម្មវិធីប្រកួតកីឡា
• កម្មវិធីអប់រំពហុមុខវិជ្ជា
• កម្មវិធីសិស្សពូកែ និងទេពកោសល្យ
• កម្មវិធីអប់រំមុខវិជ្ជាជាច្រើនទៀត !
98.7%
ក្រុមគ្រួសារនិយាយថា សាលារៀនឆាទ័រកំពុងរៀបចំឱ្យកូនៗរបស់ពួកគេទទួលបានជោគជ័យនៅពេលអនាគត់ ។
ភាពជាថ្នាក់ដឹកនាំ | ឧត្តមភាព | ភាពជោគជ័យ | ពហុវប្បធម៌
206 Jackson Street | Lowell | www.lccps.org
LCCPS LOWELL COMMUNITY CHARTER PUBLIC SCHOOL